# មរណា

# ក្រុស្សតិកម្ពុជា

ដកស្រង់ចេញពី កម្ពុជសុរិយា

## <u>អារម្ភកថា</u>

យើងបានស្កេន កាត់តដកស្រង់ពី **កម្ពុជសុរិយា** ជាច្រើន ក្បាល បញ្ចូល ជាសៀវភៅតែមួយក្បាល ដែលមានចំណងជើង និង មាតិកា ដូចច្បាប់ដើម ។

យើងចងក្រងជាសៀវភៅនេះ ដើម្បី

- ថែរក្សាស្នាដៃរបស់បុព្វបុរសខ្មែរ
- ស្រួល ក្នុងការមើលនិងស្រាវជ្រាវ
- ផ្សព្វផ្សាយ ព្រមទាំង បំរើប្រយោជន៍ សាធារណៈដោយមិនយកកំរៃ។

ធ្វើនៅញូវយ៉ក សហរដ្ឋអាមេរិក

ខែមិថុនា ឆ្នាំ២០១៧

ខៅ យុនសំរ៉ង

ប្រធាន

ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

# កម្ពុជសុរិយា

២

១៩២៧

២

– ភ្នំពេញ –

www.elibraryofcambodia.org

ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់ពីរ

លេខ ៦

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គ្វែរកណ៌មិត្ត

គ្រិ. ឆ្នាំ ១៩២៧

ព.ស. ២៤៧០

អ្នកទទួលខុសត្រូវ ជុំ-មៅ

www.elibraryofcambodia.org

# បញ្ជីរឿង


ទំព័រ

យោបុរាណក្នុងស្រុកលង្កា លោកហុការត់ចាង ហ្វាងក្រសួងវិរះរក
នោបុរាណក្នុងស្រុកលង្កាយៀបរៀង ក្រុមការ ជុំ-មៅ ធ្វើរាជការនៅ
បណ្ណាល័យកម្ពុជាប្រែជាភាសាខ្មែរ . . . . . . ៤៤៨

មនុស្សតិកម្មដ្ឋានពិស្តារ ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ អាចារ្យក្នុង
បណ្ណាល័យកម្ពុជា ប្រែចេញពីបាលីវិសុទ្ធិមគ្គ . . . ៤៥៥

មកំណើតប្រាសាទអង្គរ (តរជ្ជាតិខ្សែទី ៤) លោកល្វីហ្វីណូត៍
បង្រៀនឧត្តមវិជ្ជា សាលាក្លេសដ៏ហ្វ្រង់ឡូនៅក្រុងប៉ារីស ជាអ្នក
យក្រុមការ ជុំ មៅ ធ្វើរាជការនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែ
ជាភាសាខ្មែរ . . . . . . . . . ៤៨៦

ក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង . .
ទីនេះ មិនបានចុះផ្សាយទេ ព្រោះមានបោះចេញជាសៀវភៅហើយ)


www.elibraryofcambodia.org

# មរណានុស្សតិកម្មដ្ឋានពិស្តារ

ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ុរ

អាចារ្យក្នុងព្រះរាជបណ្ណាល័យកម្ពុជា

ប្រែចេញពីបាលីវិសុទ្ធិមគ្គ

-១-

## នឹងវិនិច្ឆ័យក្នុងមរណានុស្សតិកម្មដ្ឋាននិទ្ទេស

តត្ថ មរណស្សតិយា ភាវនានិទ្ទេសេ ក្នុងមរណានុស្សតិភាវនានិទ្ទេស នោះ មានសេចក្តីថា ព្រះយោគាវចរ នឹងចម្រើននូវមរណានុស្សតិកម្មដ្ឋាននោះ គប្បីរលឹកដល់សេចក្តីស្លាប់ ឲ្យជានិច្ចជាប់ទៅក្នុងសន្តាន ។

ឯមរណៈនោះ សំដៅយកសេចក្តីដែលដាច់ជីវិតិន្ទ្រិយ ដែលមានកំណត់ដោយភពតែ ១ គឺថាកើតឡើងក្នុងភពណា ជាសត្វមានជីវិតហើយ ដល់ចុតិទម្លាយខន្ធសូន្យដាច់ជីវិតិន្ទ្រិយ ទៅតាមភពនោះបានឈ្មោះថា មរណៈ សេចក្តីមរណៈយ៉ាងនេះ គួរនឹងយកមកជាអារម្មណ៍នៃមរណានុស្សតិកម្មដ្ឋានបាន ។

ឯមរណៈមាន ៣ ប្រការទៀតគឺ សមុច្ឆេទមរណៈ, ខណិកមរណៈ, សម្មតិមរណៈ ។ មរណៈទាំង ៣ នេះ មិនគួរនឹងយកមកជាអារម្មណ៍នៃមរណា-

www.elibraryofcambodia.org

នុស្សតិកម្មដ្ឋានហើយ សមុច្ឆេទមរណនោះ បានខាងឯព្រះអរហន្ត ដែលកាត់បង់នូវវដ្តទុក្ខ កិច្ចដែលសម្រេចដល់ព្រះអរហន្ត កាត់បង់នូវទុក្ខក្នុងសង្សារវដ្តបាននោះ ចាត់ជាមរណប្រការ ១ ហៅថាសមុច្ឆេទមរណ ខណិកមរណនោះ បានខាងសង្ខារធម៌ដែលរលត់រលាយគ្រប់ៗខណ្ឌ គឺថាចិត្តនិងចេតសិក ដែលកើតឡើងជាឧប្បាទខណ តាំងនៅជាឋិតិខណ រលត់ទៅជាភង្គខណ នោះចាត់ជាមរណប្រការ ១ ហៅថាខណិកមរណ សម្មតិមរណនោះ បានខាងសេចក្តីស្លាប់ ដែលលោកសម្មតិ ដោយលោកពោលហៅថាដើមឈើស្លាប់ ទង់ដែងស្លាប់ ដែកស្លាប់ជាដើម ចាត់ជាមរណប្រការ ១ ហៅថាសម្មតិមរណ គឺមរណទាំង ៣ ប្រការនេះ ព្រះយោគាវចរ កុំប្រាថ្នាយកមកជាអារម្មណ៍ ក្នុងកាលដែលចម្រើនមរណា-នុស្សតិកម្មដ្ឋាននោះហើយ មរណដែលគួរនឹងយកមកជាអារម្មណ៍នោះព្រះអដ្ឋកថាប្រាថ្នាយកមរណៈ ២ ប្រការ គឺ កាលមរណ ១ អកាលមរណ ១ កាលមរណនោះ គឺស្លាប់ដោយអស់បុណ្យអស់អាយុ អធិប្បាយថាសត្វទាំងពួងដែលមានកុសល ជាជនកកម្មនាំឲ្យបដិសន្ធិ ក្នុងទីដែលជាសុខ បើកុសលដែលជាឧបត្ថម្ភកតាំងទ្រនោះ មិនបានទំនុកបម្រុងហួសទៅ បើទុកជាមានបច្ច័យគឺអាហារដែលគរអាយុ នោះនៅមានបរិបូណ៌ក្តី គឺគង់មិនអាចនឹងវត្សនាការចម្រើនទៅបាន និងដល់នូវកិរិយាច្យុតិ ចាកខន្ធ ដាច់ជីវិត-ន្ទ្រិយ ព្រោះហេតុតែកុសល ឧបត្ថម្ភកនេះទៅពុំបាន មរណៈយ៉ាងនេះហៅថា បុញ្ញក្ខយមរណៈ គឺស្លាប់ដោយអស់បុណ្យ មានពាក្យដីកាតាវចូល

www.elibraryofcambodia.org

មកថា បុញ្ញក្ខយមរណៈ ស្លាប់ដោយអស់បុណ្យនេះថា ដោយសត្វដែលកើតក្នុងសម្បត្តិភព គឺភពបរិបូណ៌ដោយសម្បត្តិ ថាបើសត្វដែលកើតក្នុងវិបត្តិភព គឺភពប្រកបដោយសេចក្តីទុក្ខលំបាកដរាបដល់អស់បាប អស់អកុសលកម្មនៃខ្លួន ហើយទើបធ្វើកាលកិរិយាចាកវិបត្តិភពនោះទៅ មរណៈយ៉ាងនេះហៅថា បាបក្ខយមរណៈ ស្លាប់ដោយអស់បាប ។

ឯអាយុក្ខយមរណៈនោះ គឺស្លាប់ដោយអស់អាយុនោះ ព្រះអដ្ឋកថាលោកពោលថា សត្វដែលកេតគតិសម្បត្តិ, កាលសម្បត្តិ, អាហារសម្បត្តិមិនបាន គឺមិនបានមានគតិបរិបូណ៌ដូចទេវតា ដែលបរិបូណ៌ដោយគតិ មិនបានមានកាលដ៏បរិបូណ៌ដូចបុគ្គលក្នុងបឋមកប្ប ដែលបរិបូណ៌ដោយកាល មិនបានមានអាហារដ៏បរិបូណ៌ដូចជនក្នុងឧត្តរកុរុទ្វីប ដែលបរិបូណ៌ដោយអាហារ មានអាយុតិចប្រមាណ ១០០ ឆ្នាំ ដូចមនុស្សប្រុសស្រីក្នុងកាលសព្វថ្ងៃនេះក្តី សត្វដែលបរិបូណ៌ដោយកាល និងអាហារ និងអាយុមិនច្រើនជាង ១ សែនឆ្នាំនោះក្តី តែបណ្តាសត្វដែលស្ថិតនៅដរាបដល់អស់អាយុហើយ ទើបធ្វើកាលកិរិយាទៅទាំងប៉ុន្មាន បានឈ្មោះថាអាយុក្ខយមរណៈដូចគ្នាទាំងអស់ អ្នកប្រាជ្ញគប្បីចូលចិត្តថា សត្វដែលអស់បុណ្យ អស់បាប អស់អាយុ ហើយស្លាប់ទៅនោះ បានឈ្មោះថាកាលមរណៈ គឺស្លាប់ក្នុងកាលដ៏គួរគប្បីស្លាប់ ។

ឯអកាលមរណៈ គឺស្លាប់ក្នុងកាលដ៏មិនសមគួរនឹងស្លាប់នោះ អធិប្បាយថា សត្វទាំងឡាយដែលមានខន្ធបែកធ្លាយដោយអំណាចឧបច្ឆេទកកម្ម គឺ

www.elibraryofcambodia.org

កម្មចូលទៅផ្ដិតផ្ដាច់បង់នូវជីវិត ដូចស្ដេចទុសិមារកផងនិងស្ដេចកលាបុកផ ជាដើមដែលប្រទូសរ៉ាយដល់ខន្តីវាទីតាបស ហើយផែនដីបើកចន្លោះឲ្យធ្លាក់ ចុះទៅក្នុងអវិចីនរកនោះ បានឈ្មោះថាអកាលមរណៈ។ នេះគឺស្លាប់ក្នុងកាល មិនគួរស្លាប់ មិនតែម្យ៉ាងប៉ុណ្ណោះ សត្វទាំងឡាយដែលមានបុរាណ កម្ម មានគេមកកាប់ មកចាក់ឲ្យស្លាប់ ដោយគ្រឿងសស្ត្រាវុធធ្វើកាល កិរិយាទៅដោយព្យាយាមនៃបុគ្គលដទៃ ឬឲ្យកើតមានអកុសលចិត្តប្រហារ ជីវិតនៃខ្លួនដោយខ្លួនឯងក្ដី សេចក្ដីស្លាប់យ៉ាងនេះក៏បានឈ្មោះថាអកាល មរណៈដែរ ក៏មរណៈទាំង ២ ប្រការ គឺកាលមរណៈ និងអកាលមរណៈ មានន័យដូចពណ៌នាមកនេះ សមគួរនឹងយកមកជាអារម្មណ៍ក្នុងកាលដែល នឹងចម្រើនមរណានុស្សតិកម្មដ្ឋាននោះឯង ។

តំភាវេតុកាមេន រហោគតេន ។ល។ យោនិសោម-នសិការោ បវត្តេតព្វោ ។

សេចក្ដីថា ព្រះយោគាវចរអ្នកប្រាថ្នា នឹងចម្រើននូវមរណានុស្សតិ-កម្មដ្ឋាននោះ គប្បីចូលទៅកាន់ទីសេនាសនៈស្ងាត់នៅតែម្នាក់ឯង ហើយ គប្បីបរិកម្មថា មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ សេចក្ដីស្លាប់នឹងមានជីវិតិន្ទ្រិយនឹងដាច់ ដូច្នេះក៏បាន ឬថា មរណំ ៗ សេចក្ដីស្លាប់ៗ ដូច្នេះក៏បាន កាលដែលនឹងធ្វើបរិកម្មនោះ គប្បីតាំងមនសិការគឺធ្វើ ទុកក្នុងចិត្តជាឧបាយឲ្យមាំ កុំធ្វើមនសិការដោយឧបាយគ្មាន មានពាក្យជ-

www.elibraryofcambodia.org

កាចារ្យវិសជ្ជនាថាដែលឲ្យធ្វើមនសិការកំណត់ដោយឧបាយ គឺថាឲ្យមានសតិនឹងបញ្ញាពិចារណាឲ្យឃើញធម្មសំវេគថា សេចក្ដីស្លាប់នោះនឹងមានដល់យើងដោយពិត ជីវិតនៃយើងនេះនឹងដាច់ដោយពិត គប្បីពិចារណាឲ្យឃើញសំវេគដូច្នេះ កុំបរិកម្មទៅតែមាត់ទទេចិត្តមិនមានសំវេគសោះ បើបរិកម្មទៅតែមាត់ហើយមិនបានតាំងបញ្ញាចុះពិចារណា ឲ្យឃើញធម្មសំ-វេគក្នុងសេចក្ដីស្លាប់នោះទេ ក៏បានឈ្មោះថាធ្វើមនសិការដោយអនុបាយគ្មាន កាលបើព្រះយោគាវចរប្រព្រឹត្តនូវកិច្ចមនសិការ ដោយអនុបាយគ្មាននោះ ខណៈកាលរលឹកដល់សេចក្ដីស្លាប់ នៃបុគ្គលដែលជាទីស្រឡាញ់ ក៏កើតសេចក្ដីស្រណោះ ឧបមាដូចបុគ្គលដែលរឭកដល់មាតាបង្កើត និងកូនដែលជាទីស្រឡាញ់ដែលដល់នូវអនិច្ចកម្មកន្លងទៅ ក៏នឹងកើតសេចក្ដីសោកសេចក្ដីខ្សឹកខ្សួល កាលបើរឭកដល់សេចក្ដីស្លាប់របស់ជន ដែលខ្លួនស្អប់ខ្ពើមមិនស្រឡាញ់ ក៏នឹងកើតសេចក្ដីត្រេកអរទៅវិញ ដូចជនដែលមានពៀររលឹកដល់សេចក្ដីស្លាប់នៃខ្មាំង និង គូ កាលបើរលឹកដល់សេចក្ដីស្លាប់ នៃបុគ្គលដែលខ្លួនមិនស្អប់មិនស្រឡាញ់នោះ ក៏នឹងព្រងើយៗ មិនមានសេចក្ដីសំវេគដូចឆវឌាហកជន គឺអ្នកសម្រាប់ដុតខ្មោច កាលបើឃើញសាកសពហើយ នឹង កើតសេចក្ដីសំវេគគ្មាន ថាបើរលឹកដល់សេចក្ដីស្លាប់របស់ខ្លួនវិញ ក៏កើតសេចក្ដីតក់ស្លុតក្នុងចិត្ត ដូចបុគ្គលដែលមានសន្តានប្រកបដោយសេចក្ដីខ្លាចច្រើន កាលណាបើបានឃើញពេជ្ឈឃាដ កាន់នូវដាវលើកឡើងត្រៀមក្នុងទីចំពោះមុខ ក៏មានចិត្តនោះ

www.elibraryofcambodia.org

តក់ស្លុតក្រៃពេក សេចក្ដីនេះអ្នកប្រាជ្ញគប្បីសន្និដ្ឋានក្នុងចិត្តថា ហេតុដែលនឹងឲ្យកើតសេចក្ដីសោយសោកក្ដី សេចក្ដីត្រេកអរក្ដី សេចក្ដីកសំវេគគ្មានក្ដី សេចក្ដីតក់ស្លុតក្នុងចិត្តក្ដី ហេតុទាំងអស់នេះក៏អាស្រ័យអំពីកិរិយាប្រាសចាកសតិបញ្ញាកសំវេគគ្មាន ព្រោះធ្វើមនសិការដោយអឧបាយគ្មាន បរិកម្មថា មរណំ ១ នោះត្រឹមតែមាត់ទទេ មិនបានយកសតិបញ្ញាប្រកបចូលឲ្យឃើញធម្មសំវេគពិត ១ ផង ត្រឡប់ទៅជាដូច្នោះបាន បើធ្វើមនសិការដោយឧបាយញុំាងសតិបញ្ញា ឲ្យជ្រៀតជ្រែកចូលបានមានធម្មសំវេគ តាំងនៅក្នុងសន្ដានហើយឯណាទៀយ ក៏នឹងទៅជាដូច្នោះបាន នឹងចម្រើនជាគុណវិសេសដ៏ប្រសើរ បើទុកជាលើកដល់សេចក្ដីស្លាប់នៃបុគ្គលដ៏ជាទីស្រឡាញ់ក្ដី ក៏មិនសោយសោកលើកដល់សេចក្ដីស្លាប់នៃបុគ្គលមានពៀរដែលខ្លួនស្អប់ខ្ពើមក្ដី ក៏មិនត្រេកអរ លើកដល់សេចក្ដីស្លាប់នៃបុគ្គលដែលខ្លួនមិនស្អប់ មិនស្រឡាញ់ក្ដី ក៏មិនបានព្រងើយគន់នឹងកើតសេចក្ដីសំវេគបរិបូណ៌ទៅក្នុងសន្ដាន បើទុកជាលើកដល់សេចក្ដីស្លាប់នៃខ្លួនទៀត ក៏គង់មិនតក់ស្លុតប៉ុន្មាន និងប្រាសចាកសេចក្ដីតក់ស្លុតទៅបាន ។

តស្មា តត្ថ តត្ថ ហតមតសត្តេ ឱលោកេត្វា ទិដ្ឋបុព្វ-សម្បត្តីនំ មតានំ សត្តានំ មរណំ អាវជ្ជិត្វា សតិញ្ច សំវេគញាណញ្ច យោជេត្វា មរណំ ករស្សតិ ។

ហេតុដូច្នោះ ព្រះយោគាវចរដែលចម្រើនមរណានុស្សតិកម្មដ្ឋាននោះ

www.elibraryofcambodia.org

គប្បីពិចារណានូវសេចក្ដីស្លាប់នៃសត្វទាំងឡាយ ដែលជាសត្រូវសម្លាប់ក្ដី ស្លាប់ឯងក្ដី ដែលគេចោលទៅក្នុងទីទាំងពួង មានទីសូសានជាដើមដែលខ្លួនបានឃើញអំពីមុន គប្បីពិចារណាយកមកជាអារម្មណ៍ ក្នុងកាលដែលចម្រើនមរណានុស្សតិកម្មដ្ឋាននោះ សតិញាណបញ្ញាញាណសំវេគ-ញាណយោជេត្វា គប្បីធ្វើមនសិការដោយឧបាយ ញ៉ាំងសតិនិងបញ្ញានិងធម្មសំវេគឲ្យកើតឡើងហើយ គប្បីធ្វើបរិកម្មដោយន័យមានដើមថា មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ (សេចក្ដីប្រែដូចមុន) កាលបើព្រះយោគាវចរប្រព្រឹត្តដោយវិធី ដែលព្រះអដ្ឋកថាចារ្យសម្ដែងទុកដូច្នេះ ពួកខ្លះដែលមានបញ្ញិន្ទ្រិយមុតក្លានោះ ក៏អាចឃាត់បង់នូវនីវរណធម៌ទាំង ៥ មានកាមច្ឆន្ទជាដើម និងមានមរណារម្មណ៍តាំងមាំនិងបានសម្រេចឧបចារសមាធិ មិនបានព្រួយលំបាកពេកព្រោះមានបញ្ញិន្ទ្រិយមុតក្លា ។

ឯព្រះយោគាវចរដែលមានបញ្ញិន្ទ្រិយ មិនបានមុតក្លា ក៏មិនបានសម្រេចក្នុងកិច្ចនៃកម្មដ្ឋានវិធីប៉ុណ្ណោះទេ បើមានប្រាថ្នាចម្រើនក្នុងមរណា-នុស្សតិកម្មដ្ឋានតទៅ ក៏គប្បីរលឹកដល់សេចក្ដីស្លាប់ដោយអាការ ៨ គឺ ៖

១-វធកបច្ចុបដ្ឋាន ឲ្យព្រះយោគាវចររលឹកដល់សេចក្ដីស្លាប់ឲ្យឃើញប្រាកដ ដូចនាយពេជ្ឈឃាដដែលមានដៃកាន់ដាវដ៏មុត មានពាក្យបុច្ឆាសួរថា ហេតុអ្វីទើបឲ្យរលឹកដូច្នេះ វិសជ្ជនាថា បានជាឲ្យរលឹកយ៉ាង

www.elibraryofcambodia.org

ដូច្នេះនោះ ព្រោះឲ្យឃើញថា ការដែលកើតនិងស្លាប់នោះមកព្រមគ្នា សត្វទាំងឡាយដែលកើតមកក្នុងលោកនេះ តែងមានជរានិងទុក្ខមរណ ជាប់ប្រកបជាមួយនឹងខ្លួនមកគ្រប់រូបគ្រប់នាម យថាហិ អហិច្ឆត្តកំ មកុលំ មត្ថកេ បំសុំ គហេត្វា ឧគ្គច្ឆតិ ប្រៀបដូចក្រពុំផ្សិត ដែលដុះឡើងផុតពីផែនដី តែងនាំយកមកនូវធូលីកំទេចដីឡើងមកផង តេសំ បដិសន្ធិចិត្តំ ឧប្បាទានន្តរមេវ ជរំ បត្វា សត្វទាំងឡាយ ដែលកាន់យកនូវបដិសន្ធិកំណើតក្នុងលោកនេះចាប់ដើមអំពីបដិសន្ធិហើយ ក្នុងលំដាប់ឧប្បាទខណៈនៃបដិសន្ធិចិត្តនោះក៏ដល់នូវសេចក្តីជរានិងមរណៈ ជាប់ជិតតាមមកជាមួយនឹងខ្លួន បព្វតសិខរតោ បតិតោ សិលា-វិយ ប្រៀបដូចដុំថ្ម ដែលបែកធ្លាក់ចុះចាកកំពូលភ្នំ តែងកាន់យកនូវដើមឈើ និង គុម្ពស្មៅ ដែលជាប់ជាមួយនឹងខ្លួនមកផង មរណំ បិ-សហជាតិយា អាគតំ កិរិយាកើតនិងស្លាប់នេះ ជាប់មកព្រមគ្នា ជាមួយសហជាតធម៌ ព្រោះថាកើតមានហើយ ស្លាប់ក៏មានផង បុគ្គល ដែលកើតមកនេះ តែងនឹងស្លាប់ទៅវិញដោយពិត ចាប់ដើមអំពីកើតឡើងហើយ ក៏បែរមុខចំពោះទៅកាន់សេចក្តីស្លាប់មែនពិត ដូចព្រះអាទិត្យ ឧត្តមនាការរះឡើងហើយក៏បែរមុខចំពោះទៅកាន់ទិសអស្តង្គត មិនមានថយក្រោយត្រឡប់ចាកវិថីដំណើរនោះឡើយ ម្យ៉ាងទៀតឧបមាដូច ទឹក

www.elibraryofcambodia.org

ដែលហូរចុះមកអំពីភ្នំ ប្រព្រឹត្តទៅហើយមិនអាចត្រឡប់ក្រោយ តែបណ្តា
ដើមឈើនិងដើមស្មៅដែលធ្លាក់ចុះមកក្នុងខ្សែទឹកនោះ សូម្បីតែវត្ថុណា ១
មិនអាចត្រឡប់វិលក្រោយគ្មានឡើយ សេចក្តីនេះមានឧបមាដូចម្តេចមិញ
ជាមានឧបមេយ្យដូចអាយុសង្ខារសត្វទាំងពួង ដែលកន្លងទៅ ៗ មិនត្រឡប់
ក្រោយ តាំងមុខចំពោះទៅកាន់សេចក្តីស្លាប់ មិនរេកដូច្នោះឯង ហេតុ
ដូច្នោះ ព្រះសម្មាសម្ពុទ្ធសំដែងទុកថា យមេការត្តឹបឋមំ គព្ភេវស
តិមាណវោ អព្ភុដ្ឋិតោវសោយាតិ សគច្ឆំននិវត្តតិ
ជាសត្វដែលទៅក្នុងគភ៌នៃមាតា ចាប់ដើមអំពីរាត្រីណាតាំងបដិសន្ធិ ក្នុង
វេលារាត្រីនោះ ហើយក៏តាំងប្រែទៅ ៗ កាលដើមជាកលលរូប ហើយ
ប្រែទៅជា អព្ពុទ ជាបេសិ ជាឃន ចេះតែប្រែទៅ ៗ ដរាបដល់មរណ-
កាលជាទីបំផុត នឹងរកទៀងទេប្រាកដមិនបាន ប្រៀបដូចភពកដែលតាំង
ឡើងហើយ ក៏ដល់នូវការអណ្តែតឃ្លាតទៅ ៗ ដរាបដល់សូន្យបាត់ ។

មានពាក្យដីកាចារ្យសំដែងថា ដែលមានព្រះពុទ្ធភាសិតថា សត្វ
ដែលតាំងបដិសន្ធិ ក្នុងវេលាក្រ័យប់នោះ គឺជាដោយ យេភុយ្យន័យ
ជាធម្មតាសត្វដែលកាន់យកបដិសន្ធិ ក្នុងវេលាយប់នោះមានដោយច្រើន
ដែលនឹងកាន់យកបដិសន្ធិក្នុងវេលាកណ្តាលថ្ងៃនេះមានដោយតិច ហេតុ
ដូច្នោះអ្នកប្រាជ្ញគប្បីចូលចិត្តថា តើសព្វនោះព្រះអង្គសម្តែងដោយ យេ-
ភុយ្យន័យ ឯអាយុនៃសត្វដែលកន្លងទៅ ៗ ដោយន័យដូចពណ៌នាមក

www.elibraryofcambodia.org

ដូច្នេះ ហេតុនេះព្រះអដ្ឋកថាលោកឧបមាទុកថា ជីវិតដែលរស់ទៅតិចទៅ
នោះ ដូចអាការដែលរស់ទៅនៃទឹកក្នុងស្លឹកតិចទៅ ៗ រឿយ ៗ ដោយ
អំណាចកំដៅនៃព្រះអាទិត្យ ក្នុងគិម្ហរដូវដល់នូវសេចក្ដីហួតរីងអស់ទៅគ្រប់
ថ្ងៃគ្រប់វេលា ពុំនោះសោតដូចផ្លែឈើ ដែលអាបោធាតុមិនបានជ្រាប
ដល់ នឹងជ្រុះចាកដើមក្នុងវេលាព្រឹក ក៏ធ្លាក់ផ្លែឈើដែលមានរស មាន
ពណ៌ផ្សេង ៗ អាស្រ័យនឹងរសនៃផែនដី ដែលទឹករសើមជ្រាបឡើងទូទៅ
ក្នុងដើម ទើបដល់នូវវណ្ណាការចម្រើនទៅជាយ៉ាងល្អ បានជាបើរស
ផែនដីមិនអាចសើមជ្រាបឡើងទៅក្នុងដើមបាន ផ្លែឈើទាំងនោះ ក៏នឹង
ដល់នូវសេចក្ដីវិនាសចាកដើមមិនខាន សេចក្ដីនេះមានឧបមាដូចម្ដេចមិញ
ជាឧបមេយ្យដូចជីវិតសត្វទាំងពួងនេះ អាស្រ័យនូវរសនៃអាហារដែល
សើមជ្រាបទៅក្នុងកាយ ជាបើរសអាហារ មិនអាចជ្រាបទៅបាន
ទេ ក៏នឹងដល់នូវសេចក្ដីហួតរីងដាច់ ជីវិតិន្ទ្រិយទៅមិនខាន យ៉ាងនោះ ក៏
ឯរូបនិងនាមទាំងពួងនេះកាលបើជរា ព្យាធិ មរណៈ បៀតបៀនហើយ ក៏
ដល់នូវសេចក្ដីគ្រាំគ្រា ស្វិតស្រពោនឈឺចាប់លំបាកវេទនា មានខ្យល់
អស្សាសបស្សាសដាច់សូន្យទៅ សល់នៅតែកងកាយម្យ៉ាង ជាអសុភ
សាធារណ៍លើផែនដីដូចគ្នា ប្រៀបដូចភាជន៍ដីដែលបុគ្គលប្រហារដោយ
ដំបង នឹងបែកធ្លាយខ្ចាត់ខ្ចាយទៅដូច្នោះឯង ហេតុដូច្នោះ ព្រះសម្មាសម្ពុទ្ធ
ទ្រង់ភាសិត នូវព្រះគាថាយ៉ាងនេះទុកមក ។

www.elibraryofcambodia.org

អច្ចយន្តិ អហោរត្តា ជីវិតំ ឧបរុជ្ឈតិ អាយុ ខីយតិ
មច្ចានំ កុន្នទីនំវ ឧទកំ ផលានមិវ បក្កានំ បាតោ-
បតនតោ ភយំ ឯវំ ជាតាន មច្ចានំ និច្ចំ មរណតោ ភយំ
យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ ខុទ្ទកញ្ចម
ហន្តញ្ច យំ បក្កំ យញ្ច អាមកំ សព្វំ ភេទនបរិយន្តំ ឯវំ-
មច្ចាន ជីវិតំ ឧស្សាវោវ តិណគ្គម្ហិ សុរិយស្សុគ្គមនំ បតិ
ឯវមាយុ មនុស្សានំ មា មំ អម្ម និវារយាតិ ។

*សេចក្ដីថា ថ្ងៃនិងយប់ទាំងឡាយប្រព្រឹត្តកន្លងទៅយ៉ាងណា ជីវិតសន្ដានៃសត្វទាំងឡាយ ក៏ចេះតែរលត់បាត់ទៅ ៗ យ៉ាងនោះឯង ទឹកក្នុងស្ទឹងដែលតែងតែហូរទៅយ៉ាងណា អាយុសន្ដានៃសត្វទាំងឡាយ ក៏តែងអស់ទៅជាធម្មតាយ៉ាងនោះ ភ័យរបស់ផ្លែឈើទុំទាំងឡាយ កើតឡើងអំពីកិរិយាជ្រុះចុះចាកដើមយ៉ាងណា ភ័យនៃសត្វទាំងឡាយកើតឡើងអំពីសេចក្ដីស្លាប់ជានិច្ចយ៉ាងនោះ ភាជនដីឯណាតូច ឬ ធំ ចាស់ ឬ ថ្មី ដែលស្មូនឆ្នាំងធ្វើហើយ ហេតុដោយភាជនទាំងនោះ នឹងដល់នូវកិរិយាបែកធ្លាយជាទីបំផុតយ៉ាងណា ជីវិតសន្ដានៃសត្វទាំងឡាយក៏នឹងអន្តរាយទៅយ៉ាងនោះ ទឹកសន្សើមដែលជាប់នៅចុងស្មៅហើយហួតរីងបាត់ទៅ ព្រោះអាស្រ័យនូវកំដៅនៃព្រះអាទិត្យយ៉ាងណា អាយុសន្ដា*

www.elibraryofcambodia.org

របស់មនុស្សសត្វទាំងឡាយ គឺអស់ទៅយ៉ាងនោះឯង ហាក់ដូចជាខឹង ពោលអន្ទំមកវិញថាម្នាលអ្នក ៗ កុំយកខ្ញុំឡើយ ឯវំជាការបច្ចុប្ប-ដ្ឋានតោមរណំអនុស្សរិតព្វំ ព្រះយោគាវចរ ដែលចម្រើននូវមរណានុស្សតិកម្មដ្ឋាននោះ គប្បីរលឹកនូវសេចក្តីស្លាប់ ដោយឯក-បច្ចុប្បដ្ឋានដូចន័យដែលពោលមកនេះ ។

២. សម្បត្តិវិបត្តិ គឺឲ្យព្រះយោគាវចររលឹកនូវសេចក្តីស្លាប់ដោយការបរិបូណ៌និងវិនាស គឺឲ្យរលឹកឃើញថាសត្វទាំងពួង ដែលកើតមកនេះបរិបូណ៌ហើយមានសេចក្តីវិនាសទៅវិញ ដែលនឹងល្អនឹងចម្រើនទៅនោះកាលដែលវិបត្តិមិនទាន់មកដល់គ្របសង្កត់នៅឡើយ បើវិបត្តិមកដល់គ្របសង្កត់ហើយ នឹងវិនាសឃ្លាតចាកវត្ថុគ្រប់ប្រការ សេចក្តីល្អនឹងចម្រើនក៏បាត់ទៅ សេចក្តីទុក្ខអាក្រក់នឹងចូលមក កាយនិងចិត្តដែលធ្លាប់ជាសុខហើយក៏ត្រឡប់ជាទុក្ខវិញ មិនធ្លាប់សោយសោកហើយក៏ត្រឡប់ជាសោយសោកវិញ ដូចយ៉ាងព្រះបាទធម្មាសោករាជ ស្តេចមានបុញ្ញានុភាពសោយរាជសម្បត្តិព្រមព្រៀងដោយសេចក្តីសុខ ដល់នូវឥស្សរិយភាពជាធំក្នុងភូមិមណ្ឌលជម្ពូទ្វីប ស្តេចបានបរិច្ចាគទានក្នុងពុទ្ធសាសនា អស់ព្រះរាជ-ទ្រព្យ ១០០ កោដិ មានអាណាចក្រផ្សាយទៅខាងក្រោមផែនដី ១ យោជន៍ ខាងលើអាកាស ១ យោជន៍ ប្រកបដោយសិរីសម្បត្តិសុខយ៉ាងនេះ កាលដែលមរណមកដល់ គឺមានសេចក្តីសោកកើតឡើងចំពោះព្រះអង្គ ហើយ

www.elibraryofcambodia.org

មានព្រះភក្ត្រាបែរស្មោះទៅកាន់សេចក្ដីស្លាប់មិនត្រឡប់ក្រោយឡើយ ន័យ ១ ទៀតថា សព្វំអារោគ្យំព្យាធិបរិយោសានំ សព្វំយោព្វនំ ជរាបរិយោសានំ សព្វំជីវិតំមរណបរិយោសានំ សេចក្ដីថា ការនៃបុគ្គលមិនមានរោគគ្រប់ប្រការ គង់តែមានព្យាធិនៅបន្ទាប់ខាងមុខ កិរិយាដែលចម្រើនដោយវ័យទាំងពួង គង់តែមានជរានៅបន្ទាប់ខាងមុខ សេចក្ដីរស់នៅរាល់ថ្ងៃនេះ គង់តែមានមរណៈ នៅបន្ទាប់ខាងមុខ

សព្វោយោលោកសន្និវាសោ ជាតិយាអនុគតោ ជរាយអនុសតោ ព្យាធិនាអភិភូតោ មរណេនអព្ភាហតោ

សេចក្ដីថា សត្វទាំងពួងដែលអាស្រ័យនៅក្នុងលោកទាំងអស់ តែងមានជាតិទុក្ខប្រដេញតាមលួងលោមធ្វើឲ្យវង្វេងភ្លាត់ស្មារតី ជរាទុក្ខតែងបង្កើតឲ្យដល់នូវវិបរិត្តផ្សេងៗ ព្យាធិទុក្ខជាអ្នកតាមញាំញី បៀតបៀនឲ្យឈឺចាប់សព្វកងកាយ មរណទុក្ខជាអ្នកគ្រប់សង្កត់បំបែកទម្លាយផ្ដាច់ផ្ដិលជីវិតិន្ទ្រិយឲ្យវិនាសសាបសូន្យទៅ ហេតុនេះទើបព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងថា ៖

យថាបិសេលាវិបុលា នភំអាហច្ចបព្វតា សមន្តា
អនុបរិយេយ្យុំ និប្បោថេន្តាចតុទ្ទិសា ឯវំជរាចមច្ចុច
អធិវត្តន្តិបាណិនោ ខត្តិយេព្រាហ្មណេវេស្សេ សុទ្ទេ
ចណ្ឌាលបុក្កុសេ នកិញ្ចិបរិវជ្ជេតិ សព្វមេវាភិមទ្ទតិ
នតត្ថហត្ថីនំភូមិ នរថានំនបត្តិយា នចាបិមន្តយុទ្ធេន

www.elibraryofcambodia.org

សត្ថា ជេតវនេ វិហរតិ ។

សេចក្ដីថា ជរក្ដី មច្ចុក្ដី នឹងបានវៀរវៃលនូវបុគ្គលណា ១ មិនមានឡើយ តែនឹងគ្រប់សង្កត់ញាំញីសព្វសត្វទាំងពួងនូវទៅ គ្រប់រូបគ្រប់នាម មិនមានលើកទុកជាក្សត្រិយ៍ ជាព្រាហ្មណ៍ជាអ្នកឈ្មួញ អ្នកគ្រូ អ្នកបណ្ដាលអ្នកដោលនូវអេចម៍ សេចក្ដីមរណៈនេះ ឧបមាដូចភ្នំដែលមានថ្មជុំនាន់តែ ១ ធ្លាក់ចុះមកអំពីអាកាស ហើយវិលទៅជុំវិញក្នុងទិសទាំង ៤ សង្កត់សង្កិននូវវត្ថុទាំងពួង មិនមានវៀរទុកនូវសត្វ នឹង សង្ខារណា ១ ឡើយ បើនឹងគយុទ្ធដោយស្ដេចមច្ចុរាជនោះ មិនមែនជាវិស័យគយុទ្ធបាន ព្រោះហេតុនោះយ៉ាងមរណសង្គ្រាមនោះ មិនមានទីតាំងនៃពលដំរី ពលសេះ ពលរថ ពលថ្មើរជើង មិនមានទីតាំងដោយគូកំពែងក្ការទាំងពួង ដែលនឹងមានពលពាហនច្រើន ក៏មិនត្រូវការនឹងយកមកគយុទ្ធដោយមរណសង្គ្រាមនោះ មិនអាចនឹងយកមកតតាំងបានឡើយ ទោះបីនឹងឲ្យនូវមាសប្រាក់កែវមណីប៉ុន្មាន ១ ក្ដី ឬចេះមន្តអាគមយ៉ាងណា ១ ក្ដី ក៏មិនអាចនឹងយកមកគយុទ្ធដោយស្ដេចមច្ចុរាជនោះបានឡើយ តំរិវត្ត-បេះដូងសម្បត្តិ វិបត្តិគោ មរណំ អនុស្សរិតព្វំ ព្រះយោគាវចរកាលកំណត់នូវសេចក្ដីស្លាប់ដូច្នេះហើយ គប្បីរលឹកដល់មរណៈដោយសម្បត្តិវិបត្តិដូចន័យដែលបានពោលមកហើយនេះចុះ ។

៣- ឧបសំហរណតោ គឺឲ្យព្រះយោគាវចររលឹកដល់សេចក្ដី

www.elibraryofcambodia.org

ស្លាប់ដោយ ឧបសំហារណា គឺជាឲ្យលើកដល់សេចក្តីស្លាប់នៃបុគ្គល ដទៃ ហើយនាំចូលមកទុកដាក់ក្នុងខ្លួន កាលដែលទឹងលើកនោះ គប្បី លើកដោយអាការ ៧ ប្រការគឺ ៖

ក. យសមហគ្គតោ ឲ្យលើកដោយការច្រើនទៅដោយយស គឺជាឲ្យលើកជាស្តេចមច្ចុកដនេះ ទឹងបានគោកក្រែងថាអ្នកនេះ ជាមនុស្ស មានបរិវារច្រើនកុំបៀតបៀនឡើយ ទឹងបានគោកក្រែងថាខ្លះមិនមានអំបាល យ៉ាងស្តេចធំទាំងឡាយមានមហាសម្មតិកដ និង មន្ធាតុកដ និង មហា. សុទស្សនចក្រពត្រាធិកដ ដែលមានឥស្សរិយយស និង បរិវារយសជាយ៉ាង ច្រើន បរិបូណ៌ទៅដោយពលពាហន និង ទ្រព្យសម្បត្តិ ជានិច្ចកាល នោះ កំគង់លុះក្នុងអំណាចស្តេចមច្ចុកដទាំងអស់ ទឹង ចាំពោលទៅថាដល់ ខ្លួនអាត្មានេះ ទឹងផុតចាកអំណាចស្តេចមច្ចុកដឯណាបាន ឃំយសម- ហគ្គតោអនុស្សរិតពុំ ព្រះយោគាវចរគប្បីលើកដោយការច្រើនទៅ ដោយយសដូចពោលមកនេះ ។

ខ. បុញ្ញមហគ្គតោ ឲ្យលើកដោយការច្រើនទៅដោយបុណ្យ គឺជាឲ្យលើកដល់អ្នកមានបុណ្យទាំងឡាយ មានជោតិកសេដ្ឋី និងជដិល សេដ្ឋី និងឧគ្គសេដ្ឋី និងមេណ្ឌកសេដ្ឋី និងបុណ្ណកសេដ្ឋីជាដើម បណ្តាជន ដែលមានបុញ្ញាភិសង្ខារទាំងនោះ ជោតិកសេដ្ឋីនោះ មានប្រាង្គណ៍ប្រា. សាទ ហើយទៅដោយកែវ ៧ ប្រការ មានផ្ទៃ ៧ ជាន់ កំពែង ៧ ជាន់សុទ្ធតែ

www.elibraryofcambodia.org

ហើយទៅដោយកែវ ៧ ប្រការ ហើយមានដាំងដើមកល្បព្រឹក្សកើតឡើង
ក្នុងជ្រុងទាំង ៤ នៃប្រាសាទ កំណាត់ ១ មានទំហំមាត់ជាង ១ យោជន៍
១ ទៀតមានទំហំមាត់ កន្លះយោជន៍ ១ ទៀតមានមាត់ជាង ៣០០ សិន
១ ទៀតមានមាត់ជាង ១០០ សិន ហើយមានស្រះកែវ មកអំពីឧត្តរកុរុទ្វីប
ជាអត្តកិរិយា ឯផ្ទៃដីលសេដ្ឋីនោះទៀត មានក្អមមាសកើតឡើងខាងក្រោយ
ផ្ទះ និងកាយកើបជញ្ជូនយកប៉ុន្មាន ៗ ក៏មិនអស់មិនមានរលោះឡើយ
មេណ្ឌកសេដ្ឋីនោះ មានពពែមាសកើតឡើងដោយបុណ្យពេញទៅក្នុងទី
ប្រមាណ ៨ ករីសក្នុងពោះពពែនោះពេញទៅដោយវត្ថុទាំងពួង បើនឹង
ប្រាថ្នាវត្ថុឯណា ១ ក៏ដកយកកន្ទក់ដែលបិទមាត់ពពែនោះចេញ ហើយ
វត្ថុនោះ ៗ ក៏ហូរចេញចាកមាត់ពពែនោះមក បានសម្រេចដូចសេចក្តី
ប្រាថ្នា បុណ្ណកសេដ្ឋីនោះ កាលដើរចេញទៅភ្ជួរស្រែ អាចម៍បំណះក៏ត្រ-
ឡប់ទៅជាមាស លុះបានធ្វើជាសេដ្ឋីហើយ ទីភូមិធ្វើផ្ទះនៅនោះ ក៏មាន
កំណប់ទ្រព្យពេញក្នុងទីនោះ អ្នកមានបុញ្ញាភិសម្ភារច្រើនផ្សេង ៗ គ្នាប្លែក
វិសេសពីគ្នា ជនទាំងឡាយដទៃគេតែងពុំល្បី ថាជាអ្នកមានបុញ្ញានុភាព
ប្រាកដក្នុងលោកនេះ ក៏អ្នកទាំងអំពាលនោះ អ្នកណា ១ មិនអាចយក
ទ្រព្យទាំងនោះ មកជាផ្លូវផ្ទូវខ្លួន លោះខ្លួនឲ្យផុតចាកអំណាចនៃស្តេច
មច្ចុរាជនោះបាន សុទ្ធតែដល់នូវមរណភាព បែកធ្លាយខន្ធបាត់ទៅទាំង
អស់ មិនបាច់ពោលទៅថ្វីដល់បុគ្គលប្រាកដដូចជាអាត្មានេះឯង ធ្វើម្តេច
នឹងរួចចាកមរណភាពទៅបាន ឯវំបុញ្ញមហគ្គតោអនុស្សរិតព្វំ

www.elibraryofcambodia.org

ព្រះយោគាវចរគប្បីរលឹកដោយការច្រើន ទៅដោយបុណ្យយ៉ាងនេះ ។

ក. ថាមមហគ្គតោ ឲ្យរលឹកដោយការច្រើនទៅដោយកម្លាំង គឺថាឲ្យរលឹកដល់បុគ្គលដែលមានកម្លាំងច្រើន ប្រាកដយ៉ាងអ្នកចម្បាប់ ឈ្មោះ វាសុទេព ពលទេព ភិមសេន យុទិដ្ឋិល ហនុជាដើម បណ្ដាអ្នកទាំងឡាយនេះ ជនម្នាក់ ៗ នោះសឹងមានកម្លាំងច្រើន ។ កម្លាំងនាយខាន់ធូ ៥០០ នាក់ ទើបស្មើនឹងកម្លាំងនាយភិមសេនតែម្នាក់ ក៏បុគ្គលដែលមានកម្លាំងច្រើន ដែលគេល្បីប្រាកដក្នុងលោកនេះ ម្ដេចក៏មិនអាចតយុទ្ធដោយស្ដេចមច្ចុរាជបាន ចំណាន់បើខ្លួនអាត្មានេះ នឹងអាចតយុទ្ធឯណាបានហ្ន៎យ ឬជាមមហគ្គតោអនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹកដោយការច្រើនទៅដោយកម្លាំង ដូចពោលមកហើយយ៉ាងនេះ ។

ឃ. ឫទ្ធិមហគ្គតោ ឲ្យរលឹកដោយការច្រើនទៅដោយឫទ្ធិ គឺថាឲ្យរលឹកដល់បុគ្គលកើតមកក្នុងលោកនេ ដែលមានឫទ្ធិសក្ដានុភាពច្រើន ដោយប្រការឯណា ៗ ក្ដី ក៏មិនអាចនឹងធ្វើនូវសង្គ្រាមតនឹងស្ដេចមច្ចុរាជនោះបានអប្បាល ដូចព្រះមហាមោគ្គល្លានត្ថេរ ជាទុតិយសាវកនៃព្រះសម្មា-សម្ពុទ្ធជាម្ចាស់ ប្រកបដោយឥទ្ធានុភាព ដ៏លើសជាទីឯកទគ្គ ចំណែកខាងឫទ្ធិបណ្ដាសាវកក្នុងសាសនានេះ សាវកណា ១ នឹងមានឫទ្ធិដូចព្រះមហាមោគ្គល្លាននេះមិនមាន ព្រះមហាមោគ្គល្លាននេះ អាចញ៉ាំងវេជយន្តប្រាសាទ របស់ទេវរាជ ឲ្យកម្រើកញាប់ញ័រដោយម្រាមមេជើងទៅបាន

www.elibraryofcambodia.org

ឯកិច្ចដែលនឹងចូលឈានសមាបត្តិឲ្យយ៉ាំងឆាប់ មិនមានបុគ្គលឯណាស្មើ មានឫទ្ធិដល់ត្រឹមនេះហើយ ម្តេចក៏គង់ចូលទៅកាន់មាត់នៃមច្ចុរាជ ព្រមទាំងឫទ្ធិ ទាំងតេជៈអំណាច ប្រៀបដូចសត្វម្រឹគដែលចូលទៅកាន់មាត់នៃសរភរាជសីហ៍ ក៏យ៉ាំងដូចគ្នានេះ ធ្វើម្តេចហើយនឹងផុតអំណាចនៃស្តេចមច្ចុរាជនោះបាន បរិវេទ្ធិមហគ្គតោ អនុស្សរិត្វា ព្រះយោគាវចរគប្បីរលឹកដោយការច្រើនទៅដោយឫទ្ធិដូចពោលមកនេះ ។

៥. បញ្ញាមហគ្គតោ ឲ្យរលឹកដោយការច្រើនទៅដោយបញ្ញា គឺថាឲ្យរលឹកឃើញថា បណ្តាសត្វទាំងឡាយដែលរស់នៅក្នុងសកល-លោកមួយសកលនេះ សត្វណា ១ ដែលមានបញ្ញាឆ្លៀវឆ្លាសយ៉ាំងណា ។ ក៏គង់មិនអាចគិតរកលេសឧបាយ គេចឲ្យផុតចាកអំណាចនៃស្តេចមច្ចុរាជនោះបាន កុំបាច់និយាយឡើយដល់សត្វដទៃ ។ ដែលមានបញ្ញាបារមីតិច ពោះបើលោកមានបញ្ញាបារមីមុតក្លា ប្រាកដយ៉ាំងព្រះមហាសារីបុត្តត្ថេរ ជាបឋមសាវ័ក ប្រកបដោយបញ្ញាដ៏ក្លាហាន ចំណែកគ្រាប់ភ្លៀងធ្លាក់ចុះក្នុងវាលល្វឹងចក្រវាឡ ធ្លាក់ចុះយូរប្រមាណ ១ កល្ប ដំណក់គ្រាប់ភ្លៀងនិងល្អងគ្រាប់ភ្លៀងនោះ មានច្រើនតិចប៉ុន្មាន ។ ព្រះសារីបុត្តលោកអាចរាប់បានទាំងអស់ បណ្តាសត្វក្នុងលោកនេះ លើកទុកតែព្រះសម្មាសម្ពុទ្ធជាម្ចាស់ចេញ ក្រៅពីនោះហើយអ្នកណា ១ ឡើយក៏នឹងមានបញ្ញាច្រើនដូចព្រះសារីបុត្តនោះគ្មាន បញ្ញាព្រះសារីបុត្តនោះថា បើតែក

www.elibraryofcambodia.org

ចេញជា ១៦ ៗ ហើយលើក ១៥ ចេញ យកតែចំណែក ១ ចំណែក ១ នោះមកចែកចេញជា ១៦ ហើយលើកចេញ ១៥ ចំណែកទៀត យកតែចំណែក ១ ខាងចុងបំផុតនោះមកចែកចេញជា ១៦ ចំណែកទៀតតាមន័យដូច្នេះដល់ទៅ ១៦ ដង ហើយទើបយកបញ្ញាព្រះសារីបុត្តត្ថេរ ១ ចំណែកដែលចែកជា ១៦ ចំណែកក្នុងទីបំផុតនោះ មកប្រៀបដោយបញ្ញាបណ្ឌិតជាតិទាំងពួង ៗ ក៏គិតជាងបញ្ញាព្រះសារីបុត្តត្ថេរ ១ ចំណែកដែលជាបំផុតនោះទៀត ព្រះសារីបុត្តនេះបានជាទីឯកទគ្គ ចំណែកខាងបញ្ញាច្រើន បណ្ដាលោកដែលមានបញ្ញាច្រើន ដល់ទីបំផុតយ៉ាងនេះហើយ ក៏គង់មិនអាចនឹងកន្ទ្រង់បង់នូវអំណាចនៃស្ដេចមច្ចុរាជនោះបាន យ៉ាងខ្ញុំអាត្មានេះនឹងអាចកន្ទ្រង់នូវអំណាចនៃស្ដេចមច្ចុរាជនោះឯណាបាន បរំបញ្ញាមហាក្ខេតោ អនុស្សរិតព្វំ ព្រះយោគាវចរ គប្បីរលឹកដោយការច្រើនទៅដោយបញ្ញា ដូចន័យដែលពោលមកហើយនេះ ៗ

៨. បច្ចេកពុទ្ធតោ ឲ្យរលឹកដោយព្រះបច្ចេកពុទ្ធ គឺឲ្យរឭកថា ព្រះបច្ចេកពុទ្ធទាំងពួងនោះ ប្រកបដោយបញ្ញាពលនិងវីរិយពលបានកាច់កិនញាំញីនូវសឹកសត្រូវគឺកិលេសធម៌ទាំងពួង ហើយដល់នូវបច្ចេកពោធិញាណ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយខ្លួនឯង មិនមានគ្រូអាចារ្យប្រៀនប្រដៅឡើយ ក៏ព្រះបច្ចេកពុទ្ធប្រសើរដោយគុណយ៉ាងនេះហើយ ម្ដេចក៏គង់មិនផុតចាកអំណាចនៃស្ដេចមច្ចុរាជនោះបាន ចំណាំ

www.elibraryofcambodia.org

បើយ៉ាងតាត្នានេះនឹងគេចរួចផុតមកតែពីទីណា ឯវំបច្ចេកពុទ្ធោ អនុស្សរឹតព្វំ ព្រះយោគាវចរគប្បីរលឹកដោយព្រះបច្ចេកពុទ្ធ ដូចន័យយ៉ាងនេះ ។

៩. សម្មាសម្ពុទ្ធោ ឲ្យរលឹកដោយព្រះសម្មាសម្ពុទ្ធ គឺឲ្យរលឹកថា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះរូប ព្រះនាម ព្រះសរីរកាយដ៏វិចិត្រទៅ ដោយវត្តិសមហាបុរិសលក្ខណ គឺលក្ខណសម្រាប់មហាបុរសទាំង ៣២ និងអសីត្យានុព្យញ្ជនទាំង ៨០ គត់ ប្រសើរដោយធម្មកាយ បរិបូណ៌ដោយ កែវគោលគឺ សីលខន្ធ សមាធិខន្ធ បញ្ញាខន្ធ វិមុត្តិខន្ធ វិមុត្តិញាណទស្សនខន្ធ និងបរិសុទ្ធ ដោយអាការទាំងពួង ជាបុគ្គលដល់ហើយនូវការច្រើនទៅដោយយស ដោយបុណ្យ ដោយកម្លាំង ដោយឫទ្ធិ ដោយបញ្ញា មិនរកបុគ្គលឯណា ១ ប្រៀបផ្ទឹមជាគូស្មើមិនបាន អរហំសម្មាសម្ពុទ្ធោ សោបិសសីលវុឌ្ឍិឆាតេន មហាអគ្គិក្ខាពោធិយ ព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គបានកាច់បំបាក់នូវកាំកង់នៃសំសារចក្ក ត្រាស់ដឹងនូវធម៌ទាំងពួងដោយព្រះអង្គឯង ដោយអាការមិនបានវិបរិត ព្រះអង្គមានគុណប្រសើរយ៉ាងនេះហើយ ម្តេចឡើយក៏គង់ទ្រង់ម្ចាប់នូវសំការធម៌ទាំងពួងចូលទៅកាន់ព្រះនិព្វាន ជាស្ថានសូន្យចាកកតាចិត្តលេសដោយទទឹកកៀវតឹមរណ ព្រះអង្គប្រៀបដូចជាគំនរភ្លើងធំ ដែលជាប្រទីបពន្លឺក្នុងត្រៃភព រលមរលត់សូន្យទៅដោយអំណាចទទឹក

www.elibraryofcambodia.org

ក្បៀន ប្រវៃក្បសល្បលោយបាត់សន្ធារកេបញ្ញត្តិមិនមាន ។

បរិមហាធុតាវស្ស យញ្ញាមេត្តំមហេសិនោ ឯក-
យេនចលដ្ឋាយ មរណាំវសមាគតំ និលជ្ជំ វីតសារជ្ជំសព្វ
សត្តាភិមទ្ទនំតយំនំមានិសំសត្តំ គាចំជាតិកវិស្សុតិ ។

សេចក្តីថា ព្រះសម្មាសម្ពុទ្ធព្រះអង្គជាអ្នកស្វែងរកនូវគុណមានសីលគុណជាដើមនេះមានការគុណច្រើនយ៉ាងនេះ ម្តេចក៏គន់សេចក្តីមរណាមិនមានកោតខ្លាច មិនមានអៀនខ្មាសសោះ ក៏ឯមរណនេះ ជាសង្គ្រាមធំក្នុងផលលោកនែនញាំញីនូវសត្វទាំងពួង ទាំងឡាយ ដែលមិនមានខ្មាស មិនមានញញើត ទំនងគ្របសង្កត់នូវសត្វប្រាកដ ដូចយ៉ាងអាត្មានេះផងមិនខាន បរិសម្មាសម្ពុទ្ធតោអធុស្សរ៉ែតញុំ ព្រះយោគាវចរគប្បីរលឹកដោយព្រះសម្មាសម្ពុទ្ធដូចន័យយ៉ាងនេះ ។

ឯអាការទាំង ៧ ប្រការនោះ រួមចូលគ្នាជាបទ ១ ហៅថា ឧបសំហារណា ។

៤- កាយពហុសាធារណតោ ឲ្យព្រះយោគាវចររលឹកថា អយំកាយោ ពហុសាធារណោ អសីតិយា គាវតាំមិកកុលានំសាធារណោ សេចក្តីថារូបកាយនៃសត្វទាំងពួងរស់សាធារណខ្ទេច ដល់ពួកជន្តុទាំងឡាយ ៨០ គ្រកូល ជន្តុដែលអាស្រ័យនូវស្បែកសម្បុរថ្ងៃ ក៏ចំពាស៊ីនូវស្បែកសម្បុរថ្ងៃដែលអាស្រ័យនៅក្នុងស្បែកបន្ទាប់

www.elibraryofcambodia.org

សាច់ ក៏ចំពាស៊ីនូវស្បែកបន្ទាប់សាច់ ដែលអាស្រ័យនៅក្នុងសាច់ ក៏ចំពាស៊ីសាច់ ដែលអាស្រ័យនូវសរសៃ ក៏ចំពាស៊ីសរសៃ ដែលអាស្រ័យនូវឆ្អឹង ក៏ចំពាស៊ីឆ្អឹង ដែលអាស្រ័យនូវខួរក្នុងឆ្អឹង ក៏ចំពាស៊ីនូវខួរក្នុងឆ្អឹង ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ដង្កូវទាំងឡាយនោះ កើតក្នុងកាយ ចាស់ក្នុងកាយ ស្លាប់ក្នុងកាយ បន្ទោបង់នូវឧច្ចារបស្សាវៈក្នុងកាយ ។

កាយោ នេសំ សូតិឃរំ ចេវ គិលានសាលា ច សុសានញ្ច វច្ចកុដិ ច បស្សាវទោណិកា ។

កាយនៃយើងទាំងពួងនេះ ជាផ្ទះសម្រាប់ប្រសូតិនៃសត្វដង្កូវ ជារោងសម្រាប់ដាក់សត្វដង្កូវឈឺ ជាព្រៃសមសាន សម្រាប់គោលសាកអស្សុកដង្កូវ ជាបង្គន់ ជាស្នូកសម្រាប់ដុះឬជាសម្រាប់បន្ទោបង់នូវឧច្ចារឬបស្សាវៈនៃដង្កូវ គួរតែសង្វេគនៅនាកាយនៃយើងគេទាំងឡាយនេះ ជួនកាលដង្កូវកម្រើកជ្រួលជ្រើមឡើង ហើយក៏ដល់នូវសេចក្ដីស្លាប់ ដោយដង្កូវកម្រើកនោះក៏មាន ខាងក្នុងក្រៅកាយនេះ ទឹងមានតែពួកដង្កូវបៀតបៀនតែម្យ៉ាងក៏ទេ សឹងមានកកើតច្រើនជាងរយដំពូក បៀតបៀនក្នុងកាយនេះទៀត ហើយក៏ជាទីសាធារណៈទូទៅដល់សត្វទាំងឡាយខាងក្រៅ មានសត្វពស់ និងខ្លួយជាដើម ជាបច្ច័យនៃសេចក្ដីស្លាប់កន្លកាយនេះជាទីមុខ ត្រូវអំពីឧបទ្ទវន្តរាយទាំងពួងផ្សេងៗ ឧបមាដូចចន្លោងដែលបុគ្គលចោងទុកក្នុងទីប្រជុំផ្លូវធំទាំង ៤ ជាទីត្រូវត្រន់នៃសរ និងលំពែងធំ និងដុំថ្មជាដើម

www.elibraryofcambodia.org

ហេតុនេះព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកថា ។

នជិកិច្ឆា វកិច្ឆាធិវសេ ចិកិច្ឆេត្ត វត្តិយាបតិហិតាយ

នតិបជិសញ្ញិក្ខត្តិ ។

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានមរណសតិក្នុងសន្តាន កាលបើវេលាថ្ងៃប្រព្រឹត្តកន្លងទៅហើយ ក្រោយនឹងចូលមក គប្បីពិចារណា ដល់មរណភាពនៃអាត្មាថា ហេតុដែលនឹងឲ្យអាត្មាដល់នូវសេចក្តីអន្តរាយ ជាបច្ច័យនៃសេចក្តីស្លាប់នោះច្រើនយ៉ាងណាស់ ដូចកាលពស់ចឹក ខ្ទួយទិច ក្អែបខាំក៏មាន ដូចកាលអាហារដែលបរិភោគចូលទៅហើយមិនទ្រុឌទ្រោម ប្រមាត់កម្រើក ស្លេស្មកម្រើក ខ្យល់មានមុខដ៏មុតដូចកាំបិតចាប់ចុកក៏មាន ហេតុទាំងនេះក៏សុទ្ធតែសេចក្តីអន្តរាយ ជាបច្ច័យនៃមរណទាំងអស់ បរំកាយ ពហុសាធារណោ មរណំអនុស្សរិតព្វំ ព្រះយោគាវចរគប្បីពិចារណានូវសេចក្តីស្លាប់ ដោយកាយពហុសាធារណ យ៉ាងនេះ ។

៥-អាយុទុព្វលតោ ឲ្យព្រះយោគាវចររលឹកសេចក្តីស្លាប់ដោយ អាយុហានកម្លាំងថយ គឺឲ្យរលឹកឲ្យឃើញថា អាយុរបស់សត្វទាំងពួង តែកម្លាំងមិនមានជាទុព្វលភាពពេកណាស់ ដូចបទថា ៖

សត្តានំជីវិតំអស្សាសបស្សាសូបនិពន្ធំចេវ ឥរិយាបថូប

www.elibraryofcambodia.org

ច្ឆិន្នំច សីតុណ្ហុបច្ឆិន្នំច មហាភូតុបច្ឆិន្នំច អាហារូបច្ឆិន្នំច ។

សេចក្ដីថា ជីវិតនៃសត្វទាំងឡាយនេះ ជាប់ចំពោះដោយដង្ហើមចេញនិងដង្ហើមចូលផង ថាបើដង្ហើមចេញចូលនោះ មិនបានប្រព្រឹត្តទៅហើយ ជីវិតក៏នឹងដាច់ទៅសូន្យទៅនឹង ដល់នូវសេចក្ដីមរណភាពដោយពិត ជីវិតនេះជាប់ទៅដោយឥរិយាបថផង កាលបើឥរិយាបថទាំង ៤ ប្រព្រឹត្តទៅស្មើល្អ ជីវិតនោះក៏រស់នៅបានមិនរលត់ មិនសូន្យទៅ បើឥរិយាបថនោះប្រព្រឹត្តទៅមិនស្មើ គឺអង្គុយច្រើន ឬដេកច្រើន ឬឈរច្រើន ឬដើរច្រើនជ្រុលដោយឥរិយាបថណា ១ ហើយ ក៏ជាហេតុនឹងឲ្យអាយុនោះ តិចទៅ ជីវិតនេះជាប់ទៅដោយសេចក្ដីក្ដៅនិងត្រជាក់ផង កាលបើក្ដៅនិងត្រជាក់នោះគាំទនៅស្មើល្អ ជីវិតក៏រស់នៅប្រព្រឹត្តទៅបាន បើក្ដៅឬត្រជាក់នោះជ្រុលហួសប្រមាណហើយ អាយុក៏នឹងដាច់សូន្យទៅ ជីវិតនេះជាប់ទៅដោយមហាភូតរូប ៤ គឺធាតុទាំង ៤ កាលបើធាតុទាំង ៤ នោះប្រព្រឹត្តទៅស្មើល្អ ជីវិតក៏ចម្រើនទៅបាន បើធាតុទាំង ៤ ធាតុណា ១ ប្រព្រឹត្តទៅមិនស្មើកម្រើកហើយ អាយុនឹងដាច់សូន្យទៅ ទុកជាបុគ្គលបរិបូណ៌ដោយកម្លាំងច្រើនយ៉ាងណា ៗ ក្ដី តែធាតុណា ១ កម្រើកហើយក៏គង់នឹងមានកាយនោះ គ្រាំគ្រាជាពេកពន់ ១ មានអតិសារពេក គឺរាគចុះឈាមជាដើម មានកាយនោះពុកស្អុយសៅហ្មង ក្ដៅក្រហាយក្រវល់ក្រវាយខ្លួនទៅសព្វាង្គកាយ ជួនកាលមានទឹកដាច់ឃ្លាតចេញពីគ្នា

www.elibraryofcambodia.org

កំដាច់ជីវិតិន្ទ្រិយសូន្យទៅ ជីវិតនេះជាប់ទៅដោយអាហារ កាលបើបាន អាហារបរិភោគចូលទៅ ជីវិតក៏ប្រព្រឹត្តទៅបាន ថាបើមិនបានបរិភោគអាហារហើយ ឬបរិភោគឲ្យច្រើនកើនលើសប្រមាណ ភ្លើងធាតុមិនអាចកំដៅឲ្យជ្រុះក្រោមទៅមិនបាន ហើយអាយុក៏នឹងដាច់សូន្យទៅ អាស្រ័យហេតុនេះឯងទើបសម្តែងថា ជីវិតិន្ទ្រិយរបស់សត្វទាំងពួងនោះ ជាប់ទៅដោយអស្សាសបស្សាសផង ជាប់ទៅដោយសេចក្តីក្តៅ និង ត្រជាក់ផង ជាប់ទៅដោយមហាភូតរូបផង ជាប់ទៅដោយអាហារផង រីអាយុទុព្វលតោ មរណំអនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹកដល់សេចក្តីស្លាប់ ដោយអាយុទុព្វលដូចមានន័យដែលសម្តែងមកនេះ ។

៦ អនិមិត្តតោ ឲ្យព្រះយោគាវចររលឹកសេចក្តីស្លាប់ ដោយកំណត់គ្មានថា ៖

ជីវិតំព្យាធិ កាលោ ច ទេហនិក្ខេបនំ គតិ បញ្ចេតេ
ជីវលោកស្មឹ អនិមិត្តា ន ញាយរេ ។

អធិប្បាយថា ហេតុដែលនឹងកំណត់មិនបានរបស់សត្វនោះមាន ៥ យ៉ាង គឺជីវិតកំណត់មិនបាន ១, សេចក្តីឈឺចាប់កំណត់មិនបាន ១, កាលវេលានឹងស្លាប់កំណត់មិនបាន ១. ទីដែលនឹងទំលាក់ឡើងសាកសពកំណត់មិនបាន១, ដំណើរដែលនឹងទៅកាន់គតិខាងមុខទៀត កំណត់មិនបាន ១, រួមត្រូវជា៥ យ៉ាង អធិប្បាយថាសត្វទាំងឡាយនឹងកំណត់

www.elibraryofcambodia.org

ថា អញ្ញទីន៍មានជីវិតប្រព្រឹត្តទៅបានដល់កាលត្រឹមនោះៗ បើមិនទាន់ដល់កាលត្រឹមនោះទេ អញ្ញទីន៍មិនស្លាប់មុន លុះតែដល់កាលកំណត់នោះទើបស្លាប់ ទីន៍កំណត់យ៉ាងនេះមិនបាន កាល ល កាលេ បិ សត្តាមរត្តិ សត្វទាំងឡាយដែលកើតឡើងក្នុងគភ៌មាតានោះ ទើបទីន៍តាំងឡើងជាកលលរូបហើយវិនាសទៅក៏មាន ជាអព្វុទហើយក៏មាន ដូនកាលជាបេសិជាឃនហើយវិនាសទៅក៏មាន ដូនកាលបែកបញ្ចសាខាហើយវិនាសទៅក៏មាន ដូនកាលតាំងនៅបាន ១ ខែ ២-៣-៤-៥-១០ ខែ ហើយក៏វិនាសទៅក៏មាន សត្វដំពូកខ្លះ ស្លាប់ក្នុងកាលចេញចាកគភ៌មាតាក៏មាន សត្វខ្លះចេញចាកគភ៌មាតាហើយ តាំងនៅបាន ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ហើយស្លាប់ទៅក៏មាន នៅបាន ៤-៥-១០ ថ្ងៃស្លាប់ទៅក៏មាន នៅបាន ១ ខែ ២ ខែ ៣ ខែ ហើយស្លាប់ទៅក៏មាន នៅបាន ៤-៥-១០ ខែ ហើយស្លាប់ទៅក៏មាន នៅបាន ១-២-៣ ឆ្នាំ ហើយស្លាប់ទៅក៏មាន តាំងនៅបាន ១០-២០-៣០ ឆ្នាំ ហើយស្លាប់ទៅក៏មាន ដែលទីន៍កំណត់ជីវិតនេះកំណត់មិនបាន ឯសេចក្តីឈឺចាប់នោះទៀតក៏កំណត់មិនបានដូចគ្នា ដូចបទថា ន មិ ជា ព្យាធិ ជា សត្តា មរត្តិ ជ អញ្ចេ ជ ថាសត្វទាំងឡាយនឹងស្លាប់ដោយជម្ងឺនេះ ដោយរោគឈ្មោះនេះៗ យ៉ាងនេះកំណត់មិនបាន សត្វដំពូកខ្លះស្លាប់ដោយចក្ខុរោគគឺរោគក្នុងភ្នែក ឬសោតរោគ គឺរោគក្នុងត្រចៀក ដូនកាលស្លាប់ដោយឃានរោគ គឺរោគក្នុងច្រមុះ ឬជិវ្ហារោគ គឺរោគក្នុងអណ្តាត កាយរោគ គឺរោគក្នុងកាយ សីស

www.elibraryofcambodia.org

រោគ គឺរោគក្នុងក្បាលមានប្រការផ្សេងៗ សត្វពពួកខ្លះស្លាប់ដោយរោគ ដែលតាំងឡើងអំពីប្រមាត់ហៅថាបិត្តសមុដ្ឋានរោគ ខ្លះស្លាប់ដោយរោគ ដែលតាំងឡើងអំពីស្លេស្មហៅថាសេម្ហសមុដ្ឋានរោគយ៉ាងនេះ កាលវេលា ដែលនឹងស្លាប់នោះទៀតក៏រកកំណត់មិនបានដូចគ្នា ដូចបទថា ឥមស្មឹ យេវកាលេមរិតព្វំអញ្ញស្មឹ ថាសត្វយ៉ាងនេះត្រូវស្លាប់ក្នុងពេល ដូច្នេះ ក្រៅពីពេលនេះមិនស្លាប់ឡើយ នឹងកំណត់ដូច្នេះមិនបាន ជួន កាលសត្វខ្លះស្លាប់ក្នុងពេលព្រឹកក៏មាន សត្វខ្លះស្លាប់ក្នុងវេលាថ្ងៃត្រង់ ខ្លះ ស្លាប់ក្នុងវេលាថ្ងៃរសៀលក៏មាន ជួនកាលស្លាប់ក្នុងពេលបឋមយាម ឬ មជ្ឈិមយាម ឬ បច្ឆិមយាមក៏មាន ដែលនឹងកំណត់វេលាស្លាប់នោះ កំណត់មិនបាន ដូចន័យដែលពោលមកនេះជាដើម ។

(មានតទៅទៀត)

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ
ស្កេនជា eBook ដោយ អ៊ិន ផុន
វិច្ឆិកា ឆ្នាំ ២០១៦
គាំទ្រដោយលោក ស្រ៊ុន តាំងហ៊ាង និងលោកស្រី អ៊ឹង ស៊ុយហ៊្សរ

សូមអរគុណ
ខ្ចៅ យុនសំរ៉ង
ប្រធាន
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

# កម្ពុជសុរិយា

២

១៩២៧
២

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

— ភ្នំពេញ —

www.elibraryofcambodia.org

ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់ពីរ

ខែ ៨


ក្រុងភ្នំពេញ

រោងពុម្ពរាជការ ក្នុងវេណីមិន្ទ

គ្រិ. ឆ្នាំ ១៩២៨

ព. ស. ២៤៧០


អ្នកទទួលខុសត្រូវ ជុំ-មៅ

www.elibraryofcambodia.org

# បញ្ជីរឿង

ទំព័រ

១- សេចក្ដីអធិប្បាយពន្យល់ អំពីជើងទៀនស្បូ ដែលបានចុះភាគរៀនភាម
ក្មេ អ្នកស្រី ស៊ុយ សាន ការប៊ុន្សែស អធិប្បាយ ក្រុមការ ជុំ ម៉ៅ ប្រែ
ជាភាសាខ្មែរ . . . . . . . . . . ៥០៥
២- ធម៌ទេសនាអំពីព្រះនិព្វាន របស់លោកកុម៉ង់ដង់ វូបែរត៍ ជាងហ្វាងសា-
លាបារាំងសែស-ចិន នៅស្រុក ចំ ក្វាង (កូសាំងស៊ីន) ក្រុមការ ជុំ ម៉ៅ
ប្រែជាភាសាខ្មែរ . . . . . . . . . ៥០៨
៣- រាយការណ៍អំពីទៅពិនិត្យវត្តខ្មែរក្នុងខែត្រ កូសាំងស៊ីន ព្រះគ្រូ សង្ឃវិជ្ជា
ពាត អាចារ្យបង្រៀនភាសាសំស្ក្រឹត នៅសាលាបាលីជាន់ខ្ពស់អធិប្បាយ ៥៤៥
៤- មរណានុស្សតិកម្មដ្ឋាន ព្រះគ្រូវិមលបញ្ញា អ៊ុំ ស៊ូរ អាចារ្យព្រះរាជ
បណ្ណាល័យកម្ពុជា ប្រែចេញពីបាលីវិសុទ្ធិមគ្គ (តចប់) . . ៥៧០

www.elibraryofcambodia.org

# មរណានុស្សតិកម្មដ្ឋានពិស្ដារ

ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ

អាចារ្យក្នុងព្រះរាជបណ្ណាល័យ កម្ពុជា

ប្រែចេញពីបាលី វិសុទ្ធិមគ្គ

(តចប់)

៦ ទីដែលនឹងទំលាក់កឡេវរសាកអសុភនោះទៀត ក៏នឹងកំណត់មិនបានដូចគ្នា ដូចបទថា ឥធេវ មិយមានស្ស ទេហោ ឧបតិដ្ឋតិ អញ្ញត្រ ជាសត្វទាំងឡាយកាលស្លាប់ក្នុងទីនេះ ត្រូវទំលាក់នូវកាយក្នុងទីនេះ មិនគប្បីទំលាក់ក្នុងទីឯទៀតៗ ឡើយ ទីនឹងកំណត់ដូច្នេះមិនបាន ព្រោះជាឥត្តភាពរបស់សត្វខ្លះ កាលដែលកើតៗក្នុងស្រុក វេលាដល់ស្លាប់ទៅ ស្លាប់ទំលាក់កាយក្រៅស្រុកក៏មាន ជួនកាលសត្វខ្លះកាលដែលកើតៗក្រៅស្រុក វេលាដល់ស្លាប់ចេញទៅស្លាប់ក្រៅស្រុកក៏មាន ជួនកើតក្រៅស្រុក វេលាដល់ស្លាប់ចូលមកស្លាប់ក្នុងស្រុកក៏មាន សត្វខ្លះកាលដែលនៅៗក្នុងស្រុកនគរនេះ វេលាដល់ស្លាប់ទៅស្លាប់ក្នុងស្រុកឯណោះនគរឯណោះក៏មាន ជួនកាលដែលនៅៗក្នុងស្រុកឯណោះ នគរឯណោះ វេលាដល់ស្លាប់មកស្លាប់ក្នុងស្រុកនេះនគរនេះក៏មាន សត្វខ្លះកាលដែលនៅៗក្នុងទឹក វេលាដល់ស្លាប់មក ស្លាប់លើគោកក៏មាន

www.elibraryofcambodia.org

សត្វខ្លះកាលដែលនៅ ៗ ស៊ើគេកដល់ស្លាប់ទៅ ស្លាប់ក្នុងទឹកក៏មានដែល ខឹងកំណត់ចិត្តស្លាប់ កំណត់មិនបាន ។

ដំណើរដែលនឹងទៅកាន់ភពខាងមុខនោះទៀត ក៏កំណត់មិនបាន ដូចគ្នា ដូចបទថា ឥតោ ចុតេន ឥធ និច្ចត្តិកាពុំ ជាសត្វដែលនឹង ចុតិអំពីទីឯណោះត្រូវមកកើតក្នុងទីនេះស្រុកនេះ នគរនេះកំណត់ដូច្នេះមិន បាន ព្រោះជាសត្វទាំងឡាយជំពូកខ្លះ ចុតិអំពីទេវលោកមកកើតក្នុង មនុស្សលោកក៏មាន ជួនកាលចុតិអំពីមនុស្សលោក ហើយទៅកើតក្នុង ទេវលោកខ្លះ ទៅកើតក្នុងនរកខ្លះ អរូបកខ្លះទៅកើតក្នុងតិរច្ឆានកំណើត ខ្លះ ទៅកើតក្នុងប្រេតវិស័យខ្លះ អសុរកាយនិករខ្លះ ប្រព្រឹត្តទៅតាម សមគួរដល់កម្មជាកុសល ឬ ជាអកុសលរបស់សត្វ ដែលខំសន្សំទុកក្នុង ជាតិនេះទាំងសត្វឡើងកើត វិលស្លាប់ក្នុងគតិទាំង៥ គឺ, និរយគតិ បេ- តគតិ តិរច្ឆានគតិ មនុស្សគតិ ទេវគតិ មានឧបមាដូច ម្ដេចមិញ ជាមានឧបមេយ្យដូចគោដែលបុគ្គលចងក្នុងនឹមជាមួយគ្នា តែង ប្រព្រឹត្តទៅតាមកំណត់ និងរបៀបដូចមិនអាចនឹងដកចេញទៅបានឡើយ

៦. អនិមិត្តតោ មរណំ អនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹក ដល់សេចក្ដីស្លាប់ ដោយនិមិត្តដូចន័យដែលពោលមកនេះ ។

៧. អទ្ធាបរិច្ឆេទតោ ឲ្យព្រះយោគាវចររលឹកដល់សេចក្ដី

www.elibraryofcambodia.org

ស្លាប់ដោយឥតខ្ចាខេបរោគ្គ គឺឲ្យពោលថា មនុស្សានំ ជីវិតស្ស នាម ឋិតរហិ បរិត្តា អប្បា យោ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ ជាជីវិតនៃមនុស្សទាំងឡាយក្នុងកាលឥឡូវនេះនោះតិចពេកណាស់ ម្យ៉ាងទៀតមនុស្សណាដែលរស់នៅក្រោម ១០០ ឆ្នាំ ឬ ជាង ១០០ ឆ្នាំ នោះក៏ឃើញថាតិចមនុស្សណាស់ ច្រើនតែមនុស្សដែលមានអាយុតិចជាងចុះពី ១០០ ឆ្នាំមក នោះឃើញមានច្រើនមនុស្ស ហេតុដូច្នោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាទុកមកថា ៖

អប្បមាយុ មនុស្សានំ ហីឡេយ្យនំ សុបោរិសោ
ចរេយ្យាទិត្តសីសោវ . នត្ថិ មច្ចុស្ស នាគមោ ។

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាសប្បុរស កាលបើដឹងច្បាស់ថាអាយុនៃមនុស្សនេះតិចយ៉ាងនេះហើយ ក៏គប្បីប្រព្រឹត្តពិនិត្យមើលអាយុនៃខ្លួន កុំស្រវឹងទៅដោយអាយុ កុំចូលចិត្តកាន់យកថាអាយុនោះវែងនៅយឺនយូរពុំខាន គប្បីឧស្សាហ៍ព្យាយាមក្នុងសុចរិតធម៌ ខ្វល់ខ្វាយក្នុងគុណធម៌ ដែលនឹងឲ្យសម្រេចដល់ព្រះនិព្វាន ជាទីរម្ងាប់ទុក្ខសោកពេកគ្រប់ជំពូក គួរធ្វើអាការឲ្យបានដូចបុគ្គលដែលមានក្បាលភ្លើងឆេះ ហើយខំខ្វល់ខ្វាយរកឧបាយដើម្បីនឹងលត់ភ្លើងដែលឆេះជាប់នៅលើសីសៈនៃខ្លួន គប្បីឧស្សាហ៍គិតធម្មសំវេគដល់សេចក្តីស្លាប់ ព្រោះថាកើត

www.elibraryofcambodia.org

មកជាសត្វ ជាបុគ្គលហើយ ស្តេចមច្ចុរាជមិនមកបៀតបៀននោះមិនមាន
ឡើយ ដោយជាក់ខាត ដូចព្រះពុទ្ធភាសិតដែលសម្តែងមកហើយនេះ
រួចហើយទើបទ្រង់សម្តែងនូវអរកសូត្រនេះទៅថា ម្នាលភិក្ខុទាំងឡាយ
កាលជាតិអតីតមុននោះតថាគតកើតជាគ្រូម្នាក់ឈ្មោះថា អរកៈបានសម្តែង
ធម៌ដល់ព្រាហ្មណ៍ម្នាក់ឈ្មោះ អលង្កតព្រាហ្មណ៍ ក្នុងធម្មទេស-
នានោះ មានសេចក្តីថា ជីវិតនៃសត្វទាំងឡាយនេះមិនបានតាំងនៅយូរ
ឡើយ ប្រៀបដូចដំណក់នៃទឹកសន្សើម ដែលជាប់នៅដោយចុងស្មៅ
ហើយនឹងឆាប់សូន្យហួតបាត់ទៅដោយកម្តៅព្រះអាទិត្យ ឬ ដូចពពុះទឹក
ដែលប៉ោងឡើងដោយកំណាចកម្លាំងនៃខ្សែទឹកផ្ទប់គ្នា ហើយនឹងឆាប់បែក
ឆាប់សាយទៅ ឬ ថាជីវិតនៃសត្វទាំងពួងនេះ នឹងឆាប់លត់សាយទៅ
ដូចស្នាមគំនូសដែលគេគូសទឹក ហើយឆាប់លប់សាយបាត់ទៅ បើមិន
ដូច្នោះ ប្រៀបដូចខ្សែទឹកដែលហូរចុះមកអំពីកំពូលភ្នំ តែងមានខ្សែទឹកជំ
ចៀវពាយកនូវវត្ថុទាំងពួងជាយ៉ាងឆាប់រហ័សទៅ ឬ ដូចទឹកមាត់ដែល
បុគ្គលប្រមូលចូលគ្នា ហើយស្តោះចេញទៅនឹងឆាប់ហួតបាត់ទៅ ពុំនោះ
សោតដូចដុំសាច់ដែលបុគ្គលដាក់ចុះទៅក្នុងខ្ទះដែកដែលក្តៅនេះឆាប់ធ្វើឲ្យ
អស់អន្តរធានទៅយ៉ាងណា ជីវិតនៃសត្វទាំងពួងក៏យ៉ាងនោះឯង គឺជីវិត
នៃសត្វក្នុងកាលសព្វថ្ងៃនេះតិចពេកណាស់ ច្រើនទៅដោយសេចក្តីវិនាស

www.elibraryofcambodia.org

ទំនងទុកលំបាក ច្រើនពេកដោយសេចក្តីសោកសៅអាល័យចាំនភ្លួន បុគ្គល ដែលជាបណ្ឌិតជាគំរូកុំប្រមាទ គប្បីធ្វើការកុសលប្រព្រឹត្តនូវសាសនា ព្រហ្មចារិយ៍ក៏ការដែលកើតមកជាសត្វជាដរាបហើយដែលនឹងមិនត្រូវស្លាប់ នោះ មិនមានឡើយ តែកើតមកហើយក៏គង់មានសេចក្តីស្លាប់ គួនទំបំផុត មិនខាន ដូចសេចក្តីដែលទ្រង់សម្តែងទេសនាទុកក្នុងផលគ្គុនសូត្រនោះឯង ម្យ៉ាងទៀតព្រះអង្គទ្រង់សម្តែងថា ៖

យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អ-ហោរត្តាហំ វត្តិត្តំ ជីវេយ្យំ គតវតោ សាសនំ មនសិកា វេយ្យំ ពហុំ មេ កតំ អស្ស ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះពុទ្ធសាសនាដែលមានសម្មាចម្រើន នូវមរណានុស្សតិកម្មដ្ឋាននោះគង់ណាមួយ នឹងធ្វើមនសិការៈថា ឱហ្ន៎ ដូច ជាយើងគឹតទៅអាត្មានេះ បើជាយើងរស់នៅអស់ថ្ងៃនេះនិងយប់នេះ អាត្មា ក៏នឹងធ្វើមនសិការៈតាមពាក្យប្រៀនប្រដៅរបស់ព្រះ មានព្រះភាគ តិចួន អាត្មាត្រូវធ្វើច្រើនឡើងដោយពិត ព្រោះថាជាហេតុនឹងនាំមកនូវបដិវេធ ធម៌គឺ អរិយមគ្គ អរិយផល អាត្មានឹងប្រព្រឹត្តធ្វើនូវបព្វជិតកិច្ចជា ប្រយោជន៍របស់ខ្លួននោះឲ្យច្រើន នៅក្នុងខណៈសន្តានដកបដល់កំណត់ដ៏វែង ដែលអាត្មាប្រព្រឹត្តក្នុងថ្ងៃ ១ យប់ ១ នោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មានមរណស្សតិ គឺពុកឃើញសេចក្តីស្លាប់មានកំណត់ជីវិតត្រឹមថ្ងៃ ១

www.elibraryofcambodia.org

យប់ ១ ដោយប្រការដូច្នេះ គេថាគេហៅភិក្ខុនោះថា ជាអ្នកចម្រើនមរណស្សតិយ៉ាងទន់ទៅហើយ នៅប្រកបដោយសេចក្តីប្រមាទ ចំណែកភិក្ខុដែលមានមរណស្សតិ មានកំណត់ជីវិតអំពីពេលព្រឹកដរាបទៅដល់ពេលល្ងាចនោះក្តី ឬភិក្ខុដែលរឭកឃើញសេចក្តីស្លាប់ មានកំណត់ជីវិតត្រឹមពេលឆាន់ចង្ហាន់បាន ១ ពំនូតនោះក្តី ភិក្ខុទាំងឡាយនេះគេថាគេថាភិក្ខុនៅប្រកបដោយសេចក្តីធ្វេសប្រហែសនៅឡើយ ព្រោះចម្រើនមរណានុស្សតិដើម្បីឲ្យអស់នូវអាសវៈនោះនៅទន់ណាស់ មរណានុស្សតិនោះមិនបានក្លាហាន បើភិក្ខុណា ១ ចម្រើនមរណានុស្សតិ គឺរឭកឃើញសេចក្តីស្លាប់គ្រប់ពំនូតបាយ ឬគ្រប់ដង្ហើមចេញនិងដង្ហើមចូល ដោយគិតថាអាត្មាអញនឹងមានជីវិតរស់នៅត្រឹមពេលដែលលេបពំនូតបាយចូលទៅនេះ ឬ នឹងគិតថាអញនឹងរស់នៅត្រឹមដង្ហើមចេញចូលម្តងនេះ អាត្មានឹងធ្វើមនសិការៈតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ នឹងធ្វើបព្វជិតកិច្ចឲ្យជាប្រយោជន៍ដល់ខ្លួនឲ្យច្រើនទៅក្នុងសន្តានខ្លួន ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឃើញសេចក្តីស្លាប់គ្រប់ៗ ពំនូតបាយ ឬ គ្រប់ៗ ដង្ហើមចេញចូលយ៉ាងនេះ គេថាគេសរសើរថាជាអ្នកមានមរណស្សតិក្លាហាន ថាជាអ្នកប្រកបដោយអប្បមាទធម៌ដ៏បរិបូណ៌ នឹងបានអស់ទៅនៃអាសវធម៌ ឯអាការដែលនឹងប្រព្រឹត្តទៅនៃជីវិតនេះតិចតួចពេកណាស់ ដែលនឹងស្គាល់ដោយជីវិត

www.elibraryofcambodia.org

របស់ខ្លួនថា ជីវិតនេះនឹងឋិតនៅយឺនយូរ កាក្មាមុខជាមិនទាន់ដល់នូវមរណភាពនៅឡើយ នឹងស៊ូទ្រាំស្រួលទុកយ៉ាងនេះមិនបានឡើយ អ្នកប្រាជ្ញគប្បី សន្និដ្ឋានចូលចិត្តតាមន័យពុទ្ធភាសិត ដូចពណ៌នាមកនេះ បរិ អញ្ញាឯបរិច្ឆេទតោ មរណំ អនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹកដល់សេចក្តីស្លាប់ ដោយអន្តានបរិច្ឆេទតាមន័យដែលពោលមកនេះ ។

៨- ខណបរិត្តតោ ឲ្យព្រះយោគាវចររលឹកដល់សេចក្តីស្លាប់ដោយខណបរិត្ត គឺឲ្យរលឹកថា អតិបរិត្តោ សត្តានំ ជីវិតក្ខណោ ឯកចិត្តប្បវត្តិមត្តោយេវ ថាជីវិតក្ខណៈនៃសត្វទាំងពួងនេះតិចពេកណាស់ ប្រព្រឹត្តទៅបានមាត្រតែត្រឹមខណៈចិត្ត ១ ប៉ុណ្ណោះដែលមានព្រះពុទ្ធភាសិត សម្តែងដោយន័យមានជាដើមថា ជីវិតសត្វស្ថិតនៅយូរបាន ១០០ ឆ្នាំនោះ គឺថាដោយអំណាចជីវិតិន្ទ្រិយដែលប្រព្រឹត្តទៅដោយលំដាប់តពចៅដោយសន្តានៈវោហារហៅថាស្លាប់ បើថាដោយបរមត្ថនោះថាជីវិតសត្វប្រព្រឹត្តទៅដល់ត្រឹមភង្គខណៈនៃចិត្តណា ក៏បានឈ្មោះថាមរណត្រង់នោះ បើជីវិតនោះកើតឡើងជាឧប្បាទខណៈ តាំងនៅឋិតិខណៈឈ្មោះថាជីវិតរស់នៅ ឯខណចិត្តនេះមាន ៣ គឺ ឧប្បាទខណ ១ ឋិតិខណ ១ ភង្គខណ ១ កាលដែលជីវិតនោះប្រព្រឹត្តទៅដល់

www.elibraryofcambodia.org

ត្រឹម ឧប្បាទខណៈ ឋិតិខណៈ ឈ្មោះថារស់នៅ រលត់ទៅ ភង្គខណៈ ហើយឈ្មោះថាដាច់ទៅ កាលបើជីវិតដាច់ហើយចិត្តក៏លែងកើត ហើយ ក៏បានឈ្មោះថាសត្វស្លាប់ក្នុងគ្រានោះឯង តែថាមរណៈក្នុងភង្គខណៈនោះ ផុតវិស័យសត្វទាំងពួងនឹងដឹងបានព្រោះថាខណៈនៃចិត្តដែលប្រព្រឹត្តទៅក្នុងសន្តានយើងក្ដីសត្វទាំងពួងនេះឆាប់រហ័សណាស់ នឹងយកវត្ថុឯណាមកឧបមាប្រៀបនោះ បានដោយកម្រពេកណាស់ ដូចព្រះពុទ្ធភាសិតត្រាស់ថា ។

នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ បស្សាមិ ឯវំលហុ-បរិវត្តំ យថយិទំ ភិក្ខវេ ចិត្តំ ។

ម្នាលភិក្ខុទាំងឡាយ ចិត្តនេះមានការប្រព្រឹត្តរហ័សក្រៃពេកណាស់ រកឧបមាគិតដៃ ។ នឹងឲ្យប្រព្រឹត្តរហ័សស្មើដោយចិត្តនេះ គឺជាគតិវារ. ណារកមើលមិនឃើញ មានសូម្បីតែ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ នាយខ្មាន់ធ្នូ ៤ នាក់បានហាត់ហ្វឹកហ្វឺនស្ទាត់ជំនាញល្អក្នុងសិល្បសាស្ត្រធ្នូ ក្នុងពេល ១ នោះ ខ្មាន់ធ្នូទាំង ៤ នាក់ក៏ចេញទៅឈរនៅក្នុងទិសទាំង ៤ ហើយក៏យកព្រួញដ៏ជាក់ច្បាស់នឹងបន្ទោះធ្នូ ហើយបាញ់ចេញទៅព្រមគ្នា គ្រប់ទិសទាំង ៤ ព្រួញកំលៀនទៅក្នុងទិសទាំង ៤ ដោយកម្លាំងឆាប់រហ័ស តាមកម្លាំងព្រួញ ហើយដែលមានបុរសដែលមានកម្លាំងឆាប់រហ័សជាង

www.elibraryofcambodia.org

ខ្យល់បក់ ក៏រត់លឿនទៅក្នុងទិសខាងកើត ចាប់យកព្រួញដែលនៅក្នុងទិសខាងកើតនោះបានហើយ ត្រឡប់មកទិសខាងលិចហើយ ចាប់យកព្រួញដែលមកក្នុងទិសនោះបានទៀត ហើយរត់ទៅក្នុងទិសខាងជើងខាងត្បូង ក៏ចាប់យកព្រួញដែលទៅក្នុងទិសនោះ ៗ បានទាំងអស់មិនទាន់ធ្លាក់ដល់ដីឡើយ ក៏កម្លាំងបុរសដែលឆាប់រហ័សជាងខ្យល់យ៉ាងនេះ នឹងយកមកប្រៀបនឹងកម្លាំងសន្ទុះនៃចិត្តនេះ ក៏ប្រៀបមិនបាន ម្យ៉ាងទៀតកម្លាំងលឿនទៅនៃចន្ទមណ្ឌល ឬសុរិយមណ្ឌលក្តី ឬកម្លាំងសន្ទុះនៃទេវតាដែលលឿនទៅខាងមុខ នៃចន្ទមណ្ឌលនិងសុរិយមណ្ឌលនេះក្តី ក៏យកមកប្រៀបដោយសន្ទុះនៃចិត្តនេះក៏ប្រៀបមិនបានឡើយ ម្នាលភិក្ខុទាំងឡាយ ឯកិរិយាឆាប់រហ័សនៃចិត្តនេះ នឹងរកវត្ថុអ្វីមួយមកឧបមាឧបមេយ្យនោះមិនងាយនឹងរកបានឡើយ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ចិត្តដែលប្រព្រឹត្តទៅក្នុងសន្តានកើតហើយរលត់ ៗ ហើយកើតជាខណៈៗ គ្នានោះ នឹងបានជាប់ជាចន្លោះ ៗ គ្នានោះក៏ទេ គឺជាប់គ្នាមិនដាច់ ប្រៀបដូចខ្សែទឹកហូរដូច្នោះឯង ចិត្តឡើងកាន់វិថីហើយចុះទៅកាន់ភវង្គ ចុះទៅកាន់ភវង្គហើយឡើងមកកាន់វិថីទៀត ចិត្តនេះរលត់ចិត្តនោះកើត ចិត្តនោះកើតចិត្តនេះរលត់ជាលំដាប់ ៗ គ្នាទៅ ប្រៀបដូចកង់រថដែលវិលទៅនោះឯង ៗ

អ្នកប្រាជ្ញ គប្បីសន្និដ្ឋានថាជីវិតនៃសត្វនេះ កាលបើពោលដោយ

www.elibraryofcambodia.org

បរមត្ថនោះ មានកំណត់តែត្រឹមខណចិត្តតែ ១ រលត់ទៅកាលបើចិត្តនោះរលត់ចុះហើយ សត្វក៏ឈ្មោះថាស្លាប់ក្នុងគ្រានោះ បើចិត្តនោះរលត់ ១ ខណៈ ឬ ២ ខណៈ ៣ ខណៈសត្វក៏ឈ្មោះថាស្លាប់ម្តង ឬ ២ ដង ៣ ដង បើចិត្តនោះរលត់ ១ សែន ១ ពាន់ខណ ក៏បានឈ្មោះថាសត្វស្លាប់ ១ សែន ១ ពាន់ដង ចិត្តដែលរលត់នោះតាំងខណៈមិនបានយ៉ាងណា សេចក្តីស្លាប់របស់សត្វក៏ពាល់មិនបានយ៉ាងនោះ ស្លាប់គ្រប់ ៗ ខណចិត្តនោះ ដូចបញ្ហាដែលព្រះសម្មាសម្ពុទ្ធទេសនាទុកក្នុងអភិធម្មថា ។

អតីតេចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ អនាគតេ ចិត្តក្ខណេ ន ជីវិត្ថ ន ជីវតិ ជីវិស្សតិ បច្ចុប្បន្នេចិត្តក្ខណេ ន ជីវិត្ថ ជីវតិ ន ជីវិស្សតិ

សេចក្តីថា សត្វដែលមានជីវិតក្នុងខណចិត្តដែលជាអតីតនោះមិនមានជីវិតក្នុងខណចិត្តជាបច្ចុប្បន្ន មិនមានជីវិតក្នុងខណចិត្តជាអនាគត សត្វដែលមានជីវិតក្នុងខណចិត្តជាអនាគតនោះ មិនមានជីវិតក្នុងខណ-ចិត្តជាអតីត មិនមានជីវិតក្នុងបច្ចុប្បន្ន សត្វដែលមានជីវិតក្នុងខណចិត្តជាបច្ចុប្បន្ននោះ មិនមានជីវិតក្នុងខណចិត្តជាអតីត មិនមានជីវិតក្នុងខណចិត្តជាអនាគត បញ្ហានេះ ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាទុកដើម្បីនឹងឲ្យជនឃើញអធិប្បាយក្នុងបរមត្ថថា សត្វដែលមានជីវិតនៅក្នុងកាលតាំង

www.elibraryofcambodia.org

៣ គឺ អតីត អនាគត បច្ចុប្បន្ន នោះក្នុងកាល ១ ៗ មានខណៈ ៣ ៗ គឺ ឧប្បាទខណៈ ឋិតិខណៈ ភង្គខណៈ មានខណៈចិត្តដូច្នេះ ដូចគ្នាទាំងអស់គ្រប់ខណចិត្ត មិនបានប្លែកគ្នាក៏ទេ ។

ឯខណចិត្ត ១ ៗ នោះ មាននាមនិងរូបជាសហជាតកើតព្រមគ្នា ជាផ្នែក ៗ យ៉ាងនេះ ដូចគាថាដែលព្រះសព្វញ្ញុសម្តែងទុកថា ។

ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា ឯកចិត្ត-សមាយុត្តា លហុសោ វត្តតេ ខណោ យេ និរុទ្ធា មរន្តស្ស តិដ្ឋមានស្ស វា ឥធ សព្វេបិ សទិសា ខន្ធា គតា អប្បដិសន្ធិ-យា ។

អធិប្បាយក្នុងគាថាដើមថា សហជាតធម៌គឺជីវិតនិងអត្តភាព និងសុខ និងទុក្ខ និងសហជាតធម៌ដ៏សេសពីសុខ និងទុក្ខ និង ជីវិតិន្ទ្រិយនោះគឺសម្បយុត្តគ្រប់ ៗ ខណចិត្តក្នុងចិត្ត ១ ៗ ដូចគ្នាទាំងអស់ឯសហ-ជាតធម៌ទាំងឡាយនេះមិនបានលាយច្រឡំគ្នាក៏ទេ កើតព្រមគ្នាដោយខណចិត្តណា ក៏ជាផ្នែកញែកគ្នាទៅតាមខណចិត្តនោះ ។

ឯខណៈដែលនឹងកើតឡើងនៃសហជាតធម៌ គឺសុខនិងទុក្ខនិងជីវិតិន្ទ្រិយជាដើមនោះ ក៏ប្រព្រឹត្តទៅឆាប់រហ័សព្រមគ្នា ១ អន្លើដោយខណចិត្ត យេ និរុទ្ធា មរន្តស្ស តិដ្ឋមានស្ស វា ជាខ្ទៃ

www.elibraryofcambodia.org

បុគ្គលដែលស្លាប់   មិនដល់នូវកិរិយាលេតព្រមដោយចុតិចិត្តក៏មិនខាននៃ
បុគ្គលដែលស្លុតនៅមិនទាន់ស្លាប់   មិនដល់នូវកិរិយាលេតក្នុងកន្លងខណៈ
ក្រោយពីចុតិចិត្តក៏   មិនបាននៅកន្លងនោះដែរ   សព្វេបិ សង្ខារា ខណិ
កតា អប្បដិសន្ធិយា   ជាខន្ធទាំងឡាយទាំងពួងប្រាកដជាលេតដូច
គ្នាស្មើគ្នាទាំងអស់   តែជាខន្ធដែលលេតព្រមដោយចុតិចិត្តនោះ   មានបដិ-
សន្ធិចិត្តកើតជាប់ជាប់   គឺបដិសន្ធិចិត្តដែលកាន់យកអារម្មណ៍នៃជវនក្នុង
មរណាសន្នវិថី   មានកម្មឬកម្មនិមិត្ត ឬគតិនិមិត្តជាអារម្មណ៍នោះ   កើត
ក្នុងលំដាប់នៃចុតិចិត្ត   ចំណែកខាងខន្ធដែលលេតខាងកន្លងខណចិត្តទាំងពួង
ក្រោយពីចុតិចិត្តនោះ   មិនបានមានបដិសន្ធិចិត្តនោះកើតជាប់ជាប់ដែរ
មានតែចិត្តដទៃក្រោយពីបដិសន្ធិចិត្តនោះ   កើតជាប់ជាប់   តាមគួរដល់
អារម្មណ៍ដែលប្រព្រឹត្តក្នុងសន្តាន   អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ក្នុងមរណា-
សន្នវិថីគឺផ្លូវដែលជិតនឹងដល់មរណៈនោះកាលនៅ ១៧ ខណចិត្តទៀតនឹងដល់
ចុតិចិត្តហើយ   ខាងក្រោយចុតិចិត្តនោះ ១៧ ខណចិត្ត   មិនបានមានកម្ម
ជរូបកើតឡើងដែរ   ឯកម្មជរូបដែលកើតហើយអំពីមុននោះ   ក៏លេត
ចុះព្រមគ្នាដោយចុតិចិត្ត   កាលបើកម្មជរូបលេតហើយ   លំដាប់នោះចិត្ត-
ជរូបនឹងអាហារជរូបនោះក៏លេតទៅតាមគ្នា   នៅសល់តែឧតុជរូបប្រព្រឹត្ត
ទៅក្នុងកឡេវរសាកអសុក   ដរាបដល់តែក្លាយសាបសូន្យទៅ

www.elibraryofcambodia.org

យ៉ាងនេះឯងជាខន្ធដែលលេចទៅក្រោមដោយចុតិចិត្ត ចំណែកខណៈដែលលេចទៅក្នុងខណៈតាំងនៅនៃចុតិនោះរូបកលាបនៅកើតក ៗ មិនដាច់គ្នារហូតដូចជាអណ្តាតប្រទីប ឬខ្សែទឹកដែលប្រព្រឹត្តទៅមិនដាច់ចាកគ្នានោះឯង រូបដែលកើតឡើងមុន ៗ នោះ មានអាយុគ្រប់១៧ខណៈចិត្ត ហើយក៏លេចទៅរូបដែលមានអាយុមិនទាន់គ្រប់ក៏លេចនោះ ក៏នៅប្រព្រឹត្តទៅក្នុងសន្តាន កើតជាសន្តតិ ៗ គ្នាទៅ រូបកលាបទាំងពួងមិនដាច់ចាកសន្តាន អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា បើទុកជារូបកលាបកើតប្រជិតជាប់នៅក្តី តែខណៈចិត្តលេចនេះហើយ ក៏ចាត់ជាឈ្មោះថា ដល់នូវមរណៈពិត ។

បរិខណបរិត្តតោមរណាំមនុស្សវិតក្ក ព្រះយោគាវចរគប្បីព្យាករដល់សេចក្តីស្លាប់ ដោយខណបរិត្ត ដោយន័យដែលព្រះពុទ្ធភាសិត ត្រាស់ទេសនាដូចពណ៌នាមកនេះជំនុំអាការទាំងឡាយ ៨ ប្រការ ដូចន័យដែលសម្តែងមកហើយនេះ បើព្រះយោគាវចរបានព្យាករនូវន័យណា ១ បានធ្វើទុកក្នុងចិត្តរឿយ ៗ ចិត្តដែលមានមរណានុស្សតិកម្មដ្ឋានជាអារម្មណ៍នោះ ក៏នឹងបានសេពដោយការនៅក្បាហារ ក្នុងការចម្រើនស្មារតី ដែលមានមរណៈជាអារម្មណ៍នោះ ក៏នឹងតាំងនៅជាយ៉ាងល្អ និងឃាត់នូវនីវរណធម៌ទាំងឡាយបាន អង្គឈានក៏នឹងកើតប្រាកដ តែថាមិនបានដល់

www.elibraryofcambodia.org

អប្បនាឈាន បានតែត្រឹមឧបចារឈាន ព្រោះថាមរណារម្មណ៍ នោះជាសភាវធម៌ជាវត្ថុឲ្យកើតសំវេគពេកណាស់ កាលបើកាន់យកនូវមរណសតិជាអារម្មណ៍ហើយរឭករឿយៗ នោះតែងនាំមកនូវសេចក្ដីតក់ស្លុតចិត្តទៅក្នុងកាលមុខ ហេតុដូច្នោះភាវនាចិត្តដែលប្រកបដោយមរណ-ស្សតិនោះមិនអាចបានដល់ អប្បនាឈាន បានត្រឹម ឧបចារ-ឈាន ។

មានពាក្យពុទ្ធាជ្រៀតចូលមកថា ចុះលោកុត្តរឈាន និង ទុតិយារូបឈាន ចតុត្ថារូបឈាន មានអារម្មណ៍ជាសភាវធម៌ដែរ ឬក៏បានជាឡើងរហូតទៅ អប្បនាឈាន បាន ។

ពាក្យទទួលតបវិញថា លោកុត្តរឈាន ដែលឡើងទៅដល់ អប្បនាឈាន បាននោះ ដោយអំណាចភាវនាវិសេស គឺចម្រើនវិសុទ្ធិភាវនាឡើងទៅដោយលំដាប់ ។ អារម្មណ៍ក៏ជាសភាវធម៌ពិត តែបានអានុភាពដែលចម្រើនវិសុទ្ធិភាវនានោះឲ្យផល ទើបអាចឡើងរហូតទៅដល់អប្បនាឈានបាន ។

ឯទុតិយារូបឈាន និង ចតុត្ថារូបឈាន មានអារម្មណ៍ជាសភាវធម៌បានឡើងទៅដល់ អប្បនាឈាននោះ ដោយអំណាចអារម្មណ៍ជាសមតិក្កមភាវនានឹងទុតិយារូបនោះក្នុងវង់ នូវអារម្មណ៍នៃបឋ-

www.elibraryofcambodia.org

មានរូបចក្ខុក្ខារូបនោះគង់នឹងចង់នូវអារម្មណ៍នៃគតិយារូប ហេតុដូច្នេះ បើទុកជាអារម្មណ៍នោះ ជាសភាវធម៌ក្តី ក៏នឹងដល់នូវអប្បនាឈានបាន ដោយអារម្មណ៍ជា សមតិក្កមភាវនា ។

ក្នុងមរណានុស្សតិនេះរកសេចក្តីភាវនានឹងអារម្មណ៍សមតិក្កមភាវនា មិនមាន ហេតុដូច្នោះព្រះយោគាវចរ ដែលចម្រើន មរណានុស្សតិនោះ ទើបបានតែត្រឹម ឧបចារឈាន ។

ឯឧបចារឈាន ដែលព្រះយោគាវចរ បានក្នុងទីដែលចម្រើន មរណានុស្សតិនោះ ក៏បានដល់នូវពាក្យហៅថា មរណានុស្សតិ ឧបចារឈាន ព្រោះ ឧបចារឈាន នោះកើតឡើងដោយអំណាច ពិចារណាមរណស្សតិ នោះឯង ។

ឥមំ ចបច មរណស្សតិមនុយុត្តោ ភិក្ខុ សតតំ អប្បមត្តោ ហោតិ ។

សេចក្តីថា បុគ្គលដែលឃើញភ័យក្នុងវដ្តសង្សារ បានចម្រើននូវមរណានុស្សតិនេះ ក៏នឹងកាចលះបង់នូវសេចក្តីប្រមាទហើយ ។ ហើយមិនបាន ត្រេកអរក្នុងភពទាំងពួង នឹងលះបង់នូវសេចក្តីត្រេកអរក្នុងជីវិត នឹងជាអ្នក និន្ទាតិះដៀលនូវការជាលាមក នឹង មិនសន្សំទុកនូវបច្ច័យ នឹង ប្រាស ចាកសេចក្តីកំណាញ់ក្នុងគ្រឿងបរិក្ខារទាំងពួង ហើយនឹងដល់នូវសេចក្តី

www.elibraryofcambodia.org

សន្សំក្នុងអនិច្ចសញ្ញា តែបានឃើញនូវសេចក្តីមិនទៀងក្នុងរូបធម៌និងនាម-ធម៌ហើយនឹងបាននូវទុក្ខសញ្ញា អនត្តសញ្ញា ប្រាកដដោយអំណាចរឭក តាមអនិច្ចសញ្ញា បើបានឃើញអនិច្ចសញ្ញាហើយ ក៏ជាគុណឲ្យឃើញដល់ទុក្ខសញ្ញា និងអនត្តសញ្ញា កាលបើបានឃើញព្រះត្រៃលក្ខណញ្ញាណប្រាកដច្បាស់ក្នុងខន្ធសន្តានហើយ ដល់វេលានឹងស្លាប់ក៏មិនបានខ្លាចស្លាប់ចុំនាន និងមានស្មារតីមិនវង្វេងបាត់កុសលធម៌ ។

ឯបុគ្គលដែលមិនបានចម្រើន មរណានុស្សតិនោះ គ្រានឹងដល់មរណសម័យគឺកាលជិតនឹងស្លាប់នោះក៏កើតសេចក្តីតក់ស្លុតខ្លាចស្លាប់នោះក្រៃពេក ប្រៀបដូចបុគ្គលដែលម្រឹគកាចគ្របសង្កត់ទុកជាអាហារ ឬនៅក្នុងកណ្តាប់ដៃយក្ស ឬនៅក្នុងមាត់ពស់ដែលមានពិស ឬនៅក្នុងកណ្តាប់ដៃចោរឬពេជ្ឈឃាដដូច្នោះឯង ដែលមានសេចក្តីតក់ស្លុតយ៉ាងនេះ នោះព្រោះអាស្រ័យហេតុដែលមិនបានចម្រើន មរណានុស្សតិ នោះ ។

ឯគុណដែលចម្រើន មរណានុស្សតិ នេះ ជាបច្ច័យនឹងឲ្យសម្រេចដល់ព្រះនិព្វាន បើមិនទាន់បានសម្រេចព្រះនិព្វានក្នុងជាតិនេះទេ កាលក្ស័យខន្ធដាច់ជីវិតិន្ទ្រិយ៍ហើយ ក៏នឹងមាន សុគតិភព នៅខាងមុខ ។

គស្នាហារេអប្បមាណ គាយិកជសុមេធសោ

www.elibraryofcambodia.org

បរិមហាទុក្ខភ័យ          មរណស្សតិយាសនា

ហេតុដូច្នេះគ្រប់យោគាវចរដែលមានប្រាជ្ញាល្អ កុំគប្បីធ្វើនូវសេចក្តីប្រមាទ ហើយគប្បីឧស្សាហ៍ចម្រើននូវ មរណានុស្សតិ កាលណាដែលជាធម៌ប្រកបដោយគុណានុភាពដ៏ធំសព្វ ៗ កាលលើលោក ។

មរណានុស្សតិកម្មដ្ឋានចប់

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ
ស្កេនជា eBook ដោយ អ៊ិន ផុន
វិច្ឆិកា ឆ្នាំ ២០១៦
គាំទ្រដោយលោក ស្រ៊ុន តាំងហ៊ាង និងលោកស្រី អ៊ឹង ស៊ុយហ៊ួរ

សូមអរគុណ
ខ្ចៅ យុនសំរ៉ង
ប្រធាន
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

INSTITUT BOUDDHIQUE

www.elibraryofcambodia.org